ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# វឌ្ឍនភាពរបស់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន
# ប្រចាំឆ្នាំ ២០១០
# គាំទ្រដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

**World Bank-IDA-Grant No. H4410-KH**

រៀបរៀងឡើងដោយៈ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល

ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១

## ក. សេចក្តីផ្តើម

ការគាំទ្រដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាសមាសធាតុមួយនៃ**គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន** មានគោលដៅ ដើម្បីធ្វើអោយប្រសើរឡើងនៃសេវាកម្មដែលផ្តល់អោយដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ដើម្បីពង្រីកសេវាកម្មទាំងនេះ ទូទាំងប្រទេស និងចូលទៅដល់ផ្នែកឧស្សាហកម្មនានាយ៉ាងទូលំទូលាយ។ ដើម្បីបញ្ចប់នូវការងារ សមាសធាតុរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលអនុវត្តគម្រោងដោយ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល (ការរួមគ្នារបស់មូលនិធិ និង ក្រុមប្រឹក្សាអាជ្ញាកណ្តាល) មានបំណង ដើម្បីប្រើប្រាស់មូលនិធិរបស់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន សម្រាប់ការពង្រឹងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ការផ្តល់សកម្មភាពនៃការកសាងសមត្ថភាពសំខាន់ៗ ដល់អាជ្ញាកណ្តាល និងបុគ្គលិកនានា ការអភិវឌ្ឍន៍នៃភាពជាដៃគូរយ៉ាងទូលំទូលាយ និងរឹងមាំជាមួយនឹងភាគីពាក់ព័ន្ធនានា និង ការអនុវត្តន៍នូវយុទ្ធសាស្រ្តទំនាក់ទំនងនិងដល់ទិកន្លែងគោលដៅ ដោយរួមបញ្ចូលទាំងទំនាក់ទំនងផ្នែកផ្សព្វផ្សាយ និង ការផ្តល់នូវវគ្គបណ្តុះបណ្តាលចាំបាច់ និង សកម្មភាពនៃការកសាងសមត្ថភាព សម្រាប់ភាគីពាក់ព័ន្ធរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនានាទូទាំងប្រទេស។ យ៉ាងសំខាន់គឺ សមាសធាតុរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ផ្តល់សម្រាប់ការអភិវឌ្ឍន៍ និងការអនុវត្តន៍យុទ្ធសាស្រ្តនានា ដែលនឹងជួយអោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្លាយជាស្ថាប័នដែលមាននិរន្តភាពទៅពេលអនាគត។

គោលបំណងរួមនៃសមាសធាតុរបស់ក្រុមប្រឹក្សាអាជញាកណ្តាល នៅក្នុងគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន គឺដើម្បីរួមចំណែកធ្វើអោយបរិស្ថានអភិបាលកិច្ចប្រកបដោយប្រសិទ្ធិភាព សម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ដោយការធ្វើអោយប្រសើរឡើងនូវក៏រិតប្រព័ន្ធអាជ្ញាកណ្តាលការងារដែលដំណើការបានល្អ ក្នុងការកសាងភាពជឿទុកចិត្តបានរបស់និយោជក និង កម្មករ ដែលថា វិវាទការងារ នឹងត្រូវបានគេដោះស្រាយប្រកបដោយយុត្តិធម៌ និង ប្រសិទ្ធិភាព។

## ខ. លទ្ធផលការងារសម្រេចបាន

នេះជារបាយការណ៍សកម្មភាពប្រចាំឆ្នាំសម្រាប់ឆ្នាំ ២០១០ ដែលជាឆ្នាំទីពីរ នៃការអនុវត្តគម្រោងរបស់អភិបាលកិច្ចល្អមូលដ្ឋាន របស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។ របាយការណ៍នេះ គ្របដណ្តប់ ចាប់តាំងពី ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១០ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០។ ជាទូទៅ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបំពេញនូវសកម្មភាពស្នូលចំបងៗ បានយ៉ាងច្រើន នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ អត្ថបទសង្ខេបនេះ គូសបញ្ជាក់នូវជោគជ័យសំខាន់ៗ ដែលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបាន នៅក្នុងអំឡុងឆ្នាំទី២ នៃគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន។

### *អភិបាលកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល*

ក្នុងការឆ្លើយតបទៅនឹងសកម្មភាពអភិបាលកិច្ច មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលជាច្រើនលើក ដើម្បីសំរេចអោយបាននូវគោលដៅរបស់គម្រោង។ នៅក្នុងកិច្ចប្រជុំទាំងនេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានរាយការណ៍អំពីស្នាដៃដែលសម្រេចបាន រឿងទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ ការចុះធ្វើ

សវនកម្មហិរញ្ញវត្ថុរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ការអភិវឌ្ឍន៍នៃទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជា និងរឿងដទៃទៀតទៅដល់ក្រុមប្រឹក្សាភិបាល ដើម្បីជូនជ្រាបជាព័ត៌មានបច្ចុប្បន្នភាព ក៏ដូចជាដើម្បីសុំជាយោបល់។ ជារួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលមានចំនួន បីលើក ដែលបានរៀបចំឡើងនៅក្នុង ២០១០។ លើកទី១ ធ្វើនៅថ្ងៃទី ៦ ខែឧសភា លើកទី២ ធ្វើនៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១០។ ចុងក្រោយ មានកិច្ចប្រជុំពិសេសមួយ ដែលបានរៀបចំឡើងកាលពីថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១០ ជាមួយនឹងនាយកប្រតិបត្តិនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីវាយតម្លៃអំពីការងាររបស់គាត់។ នូវរាល់កិច្ចប្រជុំទាំងអស់នោះ យើងសង្កេតឃើញថា គ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាលបានចូលរួមយ៉ាងសកម្ម ដើម្បីធានាអោយមានគណនេយ្យភាព និង តម្លាភាពរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល។

លើសពីនេះទៀត មានការប្រជុំអាជ្ញាកណ្តាលចំនួន ៧ ដងផងដែរ ដែលបានរៀបចំឡើង នៅក្នុងកំឡុងពេលនៃរបាយការណ៍នេះ។ នៅក្នុងកិច្ចប្រជុំទាំងនេះ បានពិនិត្យអំពីលទ្ធផលសំរេចបាន និង បញ្ហា ប្រឈមនានាដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានជួបប្រទះនៅក្នុងឆ្នាំ ២០០៩ និង ២០១០ បានពិភាក្សាគ្នាអំពីសំណុំ រឿងសំខាន់ៗដែលបានធ្វើសវនាការ ការកំណត់កាលបរិច្ឆេទសំរាប់កិច្ចប្រជុំប្រចាំឆ្នាំ ការធ្វើទស្សនៈកិច្ចសិក្សាទៅ សហរដ្ឋអាមេរិកកិច្ចពិភាក្សាគ្នាអំពី (១) ការកំណត់ទីតាំងរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងប្រព័ន្ធដោះស្រាយវិវាទនៅក្នុងប្រទេសកម្ពុជា និង (២) ការប្រមូលភស្តុតាងៈ ការស្វែងរកព័ត៌មានដែលគួរអោយទុកចិត្តបានការធ្វើសន្និសីទថ្នាក់ជាតិស្តីពីការទំនាក់ទំនងវិជ្ជាជីវៈ និង ការណែនាំទៅលើការអនុវត្តន៍ដ៏ល្អបំផុតៈ *ភស្តុតាង និងគណនេយ្យភាព*។ ជាក់ស្តែង កិច្ចប្រជុំអាជ្ញាកណ្តាលបានធ្វើឡើងនៅសណ្ឋាគារ *ឡាផាវ៉ាំនដា* ដើម្បីពិភាក្សាគ្នាអំពីអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដែលបានចុះហត្ថលេខាដោយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសហព័ន្ធសហជីពនិងសម្ព័ន្ធសហជីពសំខាន់ៗទាំង ៦ កាលពីចុងខែ កញ្ញា ឆ្នាំ ២០១០។ អនុស្សរណៈនៃការ យោគយល់គ្នានេះដាក់ចេញនូវសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល សំរាប់វិវាទអំពីសិទ្ធិ ហើយគ្របដណ្តប់គ្រប់សមាជិកបច្ចុប្បន្ន និង ពេលអនាគតរបស់ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងសហជីព។ ក្នុងកិច្ចប្រជុំនេះអាជ្ញាកណ្តាលបានពិភាក្សាគ្នាអំពីការផ្លាស់ប្តូរ ដែលអាចធ្វើបានទៅលើទម្រង់នៃសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ តាមរយៈកិច្ចប្រជុំនេះ មានការព្រមព្រៀងគ្នាថា សេចក្តីបង្គាប់នេះនឹងត្រូវចែកចេញជាពីរផ្នែកៈ *ទីមួយ* គឺសំរាប់វិវាទដែលទាក់ទិននឹងប្រយោជន៍ ហើយនឹងផ្សេងទៀត គឺទាក់ទងនឹងសិទ្ធិ។ ភាគីវិវាទទាំងឡាយណាដែលត្រូវបានចងដោយអនុស្សរណៈនៃការយោគយល់គ្នានេះ នឹងត្រូវបានស្នើសុំអោយចុះហត្ថលេខាលើឯកសារដែលគេព្រមព្រៀងគ្នាលើសេចក្តីបង្គាប់ជាប់កាតព្វកិច្ចសំរាប់វិវាទអំពីសិទ្ធិ។ ការរៀបចំឡើងដោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចធ្វើអោយប្រសើរឡើងនូវបរិយាកាស សំរាប់ការអនុវត្តន៍អនុស្សរណៈនៃការយោគយល់គ្នាជាប្រវត្តិសាស្ត្រ ស្តីពីការធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់។



*<u>រូបថតទី ១:</u> កិច្ចប្រជុំអាជ្ញាកណ្តាល កាលពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១០*

ជាមួយគ្នានេះផងដែរ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង លេខាធិកាដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ កាលពីខែ មករា និង ធ្នូ ឆ្នាំ ២០១០។ ជាលទ្ធផលនៃកិច្ចប្រជុំប្រចាំឆ្នាំ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង លេខាធិកាដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្ហាញអំពីលទ្ធផលសំខាន់ៗ ដែលខ្លួនសំរេចបាន និង ការប្រឈមមុខនានា ក្នុងឆ្នាំ ២០១០ ទាក់ទងទៅនឹងការដោះស្រាយវិវាទ ការផ្តល់វគ្គបណ្តុះបណ្តាល ផែនការសំរាប់ឆ្នាំ ២០១១ និងសកម្មភាពផ្សេងៗទៀតរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង លេខាធិកាដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ អ្នកចូលរួមបានពិភាក្សាគ្នាយ៉ាងសកម្ម លើការអនុវត្តន៍នៃកិច្ចព្រមព្រៀង ស្តីពីការធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដែលនឹងមានប្រសិទ្ធិភាពចាប់ពី ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១១ នេះតទៅ។ ចុងក្រោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលេខាធិការដ្ឋានបានលើកឡើងនូវការបេជ្ញាចិត្តរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពនានា សំរាប់ឆ្នាំខាងមុខអោយបានជោគជ័យ។



*<u>រូបថតទី ២</u>: កិច្ចប្រជុំប្រចាំឆ្នាំ របស់គ្រួសារក្រុមប្រឹក្សាអាជ្ញាកណ្តាល កាលពីថ្ងៃទី ១៧-១៩ ខែ ធ្នូ ឆ្នាំ ២០១០ នៅខេត្ត ព្រះសីហនុ*

***ក្រុមការងារអាជ្ញាកណ្តាល***

នៅក្នុងឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបន្តការងារប្រើប្រាស់ក្រុមការងារ ដើម្បីអនុវត្តនូវការផ្តួចផ្តើម សំរាប់ការអភិវឌ្ឍន៍ស្ថាប័ន។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្កើត ក្រុមការងារអាជ្ញាកណ្តាល ចំនួនបី ដែលសមាសភាពចូលរួម ដូចជា អាជ្ញាកណ្តាល មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខាធិកាដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីគាំទ្រដល់អាជ្ញាកណ្តាល ទាក់ទងទៅនឹងផ្នែករដ្ឋបាល ក៏ដូចជាផ្នែកច្បាប់។ ក្រុមការងារនៅក្នុងឆ្នាំ ២០១០ នេះ បានបង្កើត **សេចក្តីណែនាំអំពីភស្តុតាង** សំរាប់ក្រុមអាជ្ញាកណ្តាលដើម្បីប្រើប្រាស់ (បានរំពឹងថានឹងបញ្ចប់នៅខែ មីនា ឆ្នាំ ២០១១) និងបានចាប់ផ្តើមការងារពង្រាង **គោលនយោបាយអំពីទំនាស់ផលប្រយោជន៍** ដែលនឹងយកមកអនុវត្ត សំរាប់រាល់អាជ្ញាកណ្តាលទាំងអស់ ដើម្បីធានាអោយបាននូវសេចក្តីសុច្ចរិត នៃអជ្ញាកណ្តាលទាំងឡាយ និងភាពឯករាជ្យនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល (បានរំពឹងថា នឹងបញ្ចប់នៅខែ មេសា ឆ្នាំ ២០១១)។

កាលពីថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើបទបង្ហាញអំពី ការសិក្សាលើ ***"ការស្វែងយល់អំពី បទពិសោធន៍នៃការប្រគល់ភស្តុតាង នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងចំណោមនិយោជិត និងនិយោជក ដើម្បីការដោះស្រាយវិវាទការងាររួម"*** ដល់បុគ្គលិកពាក់ព័ន្ធរបស់មូលនិធិ និង លេខាធិការដ្ឋាន។ ការស្រាវជ្រាវបែបបរិមាណវិស័យ ត្រូវបានគេរៀបចំឡើង ដើម្បីទទួលបាននូវព័ត៌មានមូលដ្ឋាន មុននឹងពង្រាងសេចក្តីណែនាំអំពីភស្តុតាង សំរាប់ណែនាំដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងការគោរព តាមច្បាប់បង្ហាញភស្តុតាង។ ការសិក្សាស្រាវជ្រាវតាមរយៈការប្រើប្រាស់ការសម្ភាសន៍របៀបស៊ីជំរៅ ជាមួយនឹងតំណាងចំនួន ២២នាក់ មកពីសហព័ន្ធសហជីព និយោជក និងអាជ្ញាកណ្តាល គឺត្រូវបានគេជ្រើសរើសដើម្បីសម្ភាសន៍ ដោយផ្អែកលើបទពិសោធន៍នានារបស់ពួកគេ នៃការជាប់ទាក់ទិនទៅនឹងការដោះស្រាយវិវាទការងារនៅអាជ្ញាកណ្តាល។ បន្ទាប់មក មូលនិធិ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានឯកភាពគ្នាបង្កើតក្រុមការងារអាជ្ញាកណ្តាលមួយ សំរាប់ការធ្វើ *"សេចក្តីណែនាំអំពី ភស្តុតាង"* កាលពីដើមខែ មេសា ដូចដែលបានបញ្ជាក់ខាងលើ។

## *ដំណោះស្រាយវិវាទការងារ*

នៅក្នុងការងារដោះស្រាយវិវាទការងារ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដើរតួយ៉ាងសំខាន់ ដើម្បីសម្របសម្រួល និងគាំទ្រដល់ការងារស្នូលរបស់ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៃការដោះស្រាយវិវាទរវាងកម្មករ និងនិយោជកនៅក្នុងប្រទេសកម្ពុជា។ នៅចុងអំឡុងពេលនៃរបាយការណ៍នេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលបានសំណុំរឿងចំនួន ១៤៥ សំណុំរឿង (លេខចុះបញ្ជី ០១/១០-១៤៥/១០)។ ទោះជាយ៉ាងណាក៏ដោយ តួរលេខនៃសំណុំរឿងដែលត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺទាបជាង បើធៀបជាមួយនឹងឆ្នាំ ២០០៩ កន្លងៗទៅ ដោយសារតែមូលហេតុមួយចំនួន។ *មូលហេតុទីមួយ* ដោយសារតែការសហជីពពីរសំខាន់ៗ គឺឈ្មោះ សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និង សហព័ន្ធសហជីពយុវជនខ្មែរ បានបំបែកខ្លួនទៅជាសហជីពតូចៗ ដែលខ្វះការរៀបចំ និងប្រសិទ្ធិភាព ក្នុងការប្តឹងពីវិវាទការងារ។ *មូលហេតុទីពីរ* សហជីព និង កម្មករបានព្យាយាមដោះស្រាយ វិវាទការងាររបស់ខ្លួននៅកំរិតរោងចក្រ ជៀសជាងនៅស្ថាប័នផ្សេងៗ។

នៅក្នុងការដោះស្រាយសំណុំរឿងវិវាទការងារនៅក្នុងឆ្នាំ ២០១០នេះ (មានសំណុំរឿងខ្លះបានបន្តតាំងតែពីឆ្នាំចាស់) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្សះផ្សាដោយជោគជ័យចំនួន ៣៩ សំណុំរឿង និងបានចេញសេចក្តីបង្គាប់ចំនួន ៩៨ សំណុំរឿង។ នៅចុងក្រោយនៃអំឡុងពេលរាយការណ៍នេះ មាន ៦សំណុំរឿងមិនទាន់បានដោះស្រាយ។ លទ្ធផលជារួម បង្ហាញថា ២៧៨ សំណុំរឿង (ឬ ២៨,៤៣%) ក្នុងចំណោម ៩៧៨សំណុំរឿង គឺត្រូវបានផ្សះផ្សារ មុនពេលសេចក្តីបង្គាប់អាជ្ញាកណ្តាល (ការព្រមព្រៀងគ្នាមុនពេលបើកសវនការ ក្នុងអំឡុងពេលសវនការ និងក្រោយពេលបើកសវនការ) ៦៥២ សំណុំរឿង (ឬ ៦៦,៦៧%) ត្រូវបានដោះស្រាយតាមរយៈការចេញសេចក្តីបង្គាប់ ៦សំណុំរឿង (ឬ ១%) ត្រូវបានមិនទាន់បានដោះស្រាយ និង ៤២ សំណុំរឿង (ឬ ៤,៤២%) ត្រូវបានត្រូវបានសម្រេចសេចក្តីដោយការដកពាក្យបណ្តឹង។

*ចំនួនសំណុំរឿងដែលទទួលបាន (ឧសភា ២០០៣ ដល់ ខែធ្នូ ឆ្នាំ ២០១០)*




ក្រាហ្វិចខាងលើនេះ បង្ហាញពីតួរលេខសំណុំរឿងដែលបានទទួលចាប់តាំងពីខែ ឧសភា ឆ្នាំ ២០០៣ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០។ តាមការបែងចែកជាវិស័យ (ដោយគិតរាល់សំណុំរឿងដែលបានទទួលតាំងពីឆ្នាំ ២០០៣ រហូតដល់ ២០១០ គឺមានសរុបចំនួន ៩៧៨ សំណុំរឿង) ៩២% នៃសំណុំរឿងគឺមកពីវិស័យកាត់ដេរសំលៀកបំពាក់ និងនៅសល់ ៨% ទៀត គឺមកពីវិស័យមិនមែនកាត់ដេរសំលៀកបំពាក់ (ដោយគិតបញ្ចូលទាំង វិស័យបដិសណ្ឋារកិច្ច និង ទេសចរណ៍ ផលិតកម្ម និង សេវាកម្ម)។ បើប្រៀបធៀបទៅនឹងចំនួនដែលបានកំណត់ទុកមុន ថា ១០% នៃសំណុំរឿង គួរតែមកពី វិស័យមិនកាត់ដេរសំលៀកបំពាក់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេច ២%ទាបជាង។ ទោះជាយ៉ាងណាក៏ ដោយ បើគិតតែក្នុងមួយឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿង ពីវិស័យមិនមែនកាត់ដេរ សំលៀកបំពាក់ចំនួន ១៤% (២១ ក្នុងចំណោម ១៤៥សំណុំរឿង) ដែលខ្ពស់ជាងចំនួនដែលបានកំណត់ទុក។

ចំនួនជាក់ស្តែងសរុបនៃសំណុំរឿង តាមតំបន់ សំរាប់ក្រៅពីភ្នំពេញ និងខេត្តកណ្តាល គឺស្មើនឹង ១%ទាបជាងចំនួនដែលបានកំណត់ទុកនៅក្នុងផែនការប្រចាំឆ្នាំ។ មូលហេតុដែលធ្វើអោយ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនអាចសម្រេចនូវចំនួនដែលបានកំណត់ទុក ដោយសារតែ សកម្មភាពសេដ្ឋកិច្ចនៃភាគីវិវាទនានា ដែលមកដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺវិស័យកាត់ដេរសំលៀកបំពាក់ រោងចក្រវាយនភ័ណ្ឌ រោងចក្រស្បែកជើង ដែលភាគច្រើន គឺប្រមូលផ្តុំគ្នា នៅតែតំបន់ភ្នំពេញ និងខេត្តកណ្តាល។




*រូបថតទី ៣: អំឡុងពេលសវនការ នៃសំណុំរឿង មេនបាធេន កាលពីថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១០*

ដើម្បីតាមដានអំពីប្រសិទ្ធិភាពនៃការដោះស្រាយវិវាទ តាមរយៈដំណើរការអាជ្ញាកណ្តាល មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការតាមដានលើលទ្ធផលនៃសំណុំរឿងដែលបានទទួល តាមរយៈការទូរស័ព្ទ ទាក់ទងទៅភាគីពាក់ព័ន្ធនៃវិវាទ រវាង ៦០-៩០ថ្ងៃនៃការចេញសេចក្តីបង្គាប់ (នៅចុងត្រីមាសនីមួយៗ)។ អត្រាជោគជ័យនៃការដោះស្រាយវិវាទការងារជាទូទៅ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចាប់តាំងពីខែ ឧសភាឆ្នាំ ២០០៣ ដល់ដំណាច់ឆ្នាំ ២០១០ គឺស្មើនឹង *៧០,១១%*។ វាមានការកើនឡើងបន្តិចបន្តួច បើប្រៀបធៀបនឹងឆ្នាំ ២០០៩ (៦៩,០៤%)។ ប៉ុន្តែ បើគិតតែក្នុងឆ្នាំ ២០១០ អត្រាជោគជ័យ គឺស្មើនឹង *៧៥,៦៦%* ខណៈដែលក្នុងឆ្នាំ ២០០៩ គឺស្មើនឹង ៧០,៤៨%។

## ***ការកសាងសមត្ថភាពសំរាប់ស្ថាប័ន និងបុគ្គលិក***

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបន្តផ្តល់សកម្មភាពនានា ដើម្បីពង្រីកការកសាងសមត្ថភាពរបស់បុគ្គលិក និង ស្ថាប័ន ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បាន រៀបចំទួរទស្សនៈកិច្ចសិក្សាទៅសហរដ្ឋអាមេរិក កាលពីថ្ងៃទី ២២-២៩ ខែ ឧសភា ឆ្នាំ ២០១០ សំរាប់សហគមន៍អាជ្ញាកណ្តាល។ ប្រតិភូគឺមានដូចជា អាជ្ញាកណ្តាល *ស៊ុន គីមស៊ាន* លោក *គង់ ផល្លះ* អាជ្ញាកណ្តាល *សេង វុចហ៊ុន* ជាក្រុមប្រឹក្សាអាជ្ញាកណ្តាល, លោក *សុខ ឡោ* ជានាយកប្រតិបត្តិ និង *មួយលី វិច្ឆរ៉ា* ជាមន្ត្រីផ្នែកច្បាប់របស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំង លោក *ជ្រុន ថៅរ៉ាវង្ស* ជាមន្ត្រីនៃលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ អគ្គនាយកដ្ឋានការងារ នៃក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ ក៏បានចូលរួមនៅក្នុងដំណើរនេះផងដែរ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ជាមួយនឹងអ្នកជំនាញការ ដែលជាប់ទាក់ទងនឹងវិស័យទំនាក់ទំនងវិជ្ជាជីវៈនៅសហរដ្ឋអាមេរិក ដោយរួមមាន អាជ្ញាកណ្តាល និង អ្នកផ្សះផ្សារបស់ National Academy of Arbitrators (NAA) និង American Arbitration Association (AAA)។ ប្រតិភូ បានជួបជាមួយ

នឹងនាយករបស់ Federal Mediation and Conciliation Services (FMCS) ដើម្បីពិភាក្សាគ្នាលើលទ្ធភាពនៃការផ្តល់ការបណ្តុះបណ្តាល ដល់អ្នកផ្សះផ្សារបស់ក្រសួងការងារ និង បណ្តុបណ្តាលវិជ្ជាជីវៈ និងអាជ្ញាកណ្តាល របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប្រតិភូមានឱកាសដើម្បី ពិភាក្សាគ្នាជាមួយ Joanne Goldstein ដែលជាលេខាធិការការងាររបស់ រដ្ឋម៉ាសាឈូសេត លើលទ្ធភាពនៃការផ្តល់មូលនិធិរបស់សហរដ្ឋអាមេរិក សំរាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងក្រសួងការងារនិងបណ្តុបណ្តាលវិជ្ជាជីវៈ។ ប្រតិភូរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានផ្លាស់ប្តូរបទពិសោធន៍គ្នាដែលមាននៅប្រទេសកម្ពុជា ជាមួយនឹងសមាជិកនានា នៃ សកលវិទ្យាល័យច្បាប់ បូស្តុនផងដែរ។



*រូបថតទី ៤: ទស្សនកិច្ចសិក្សានៅសហរដ្ឋអាមេរិច កាលពីថ្ងៃទី ២២-២៩ ខែ ឧសភា ឆ្នាំ ២០១០*

កាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ដល់ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០ ប្រតិភូ ៤រូបមកពីអាជ្ញាកណ្តាល បានធ្វើការផ្លាស់ប្តូរទស្សនៈកិច្ចសិក្សាជាអន្តរជាតិ ទៅកាន់ Fair Work Australia (FWA) នៅក្នុងប្រទេសអូស្ត្រាលី ដែលជាសមភាគីអូស្ត្រាលីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប្រតិភូរួមមាន អាជ្ញាកណ្តាល *យូ សួនទី* ជាអាជ្ញាកណ្តាលមកពីក្រុមប្រឹក្សាអាជ្ញាកណ្តាល អ្នកស្រី *ប៊ូ ច័ន្ទវាសនា* ជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សា អាជ្ញាកណ្តាល អ្នកស្រី *ស៊ូ សោភា* ប្រធានផ្នែកសេវាច្បាប់ និង លោក *វណ្ណដេត តារារដ្ឋ* ជាមន្ត្រីទំនាក់ទំនង។ តាមរយៈការធ្វើការងារមួយទល់មួយជាមួយគ្នារវាងអាជ្ញាកណ្តាល និង បុគ្គលិករបស់ Fiar Work Australia ប្រតិភូបាននូវការស្វែងយល់ស៊ីជំរៅអំពីប្រព័ន្ធប្រតិបត្តិការណ៍ទូទៅ រចនាសម្ព័ន្ធគ្រប់គ្រងសំណុំរឿងវិវាទ និង ការផ្សះផ្សារ និងជំនាញមជ្ឈត្តិកម្ម។ អ្នកចូលរួមបានរកឃើញថា ចំណេះដឹង និងបទពិសោធន៍បន្ថែម គឺមានសារៈប្រយោជន៍ សំរាប់ការធ្វើអោយប្រសើរឡើងនូវសមត្ថភាពរបស់ខ្លួន ដើម្បីដោះស្រាយវិវាទការងារ ការគ្រប់គ្រងសំណុំរឿង និង សេវាកម្មផ្សព្វផ្សាយ។

ជាមួយគ្នានេះផងដែរ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចាត់អោយបុគ្គលិករបស់ខ្លួន និង លេខាធិការដ្ឋាន អោយចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា ដើម្បីកសាងសមត្ថភាពរបស់ពួកគេ ដូចជា ច្បាប់ពន្ធដារ បច្ចេកទេសសំរាប់ការផ្សះផ្សារ វគ្គការពារអគ្គីភ័យ ការបញ្ច្រាបយេនឌ័រ ការចុះហត្ថលេខាតាមអេឡិចត្រូនិច និងការប្រគល់នូវពាក្យស្នើសុំដកចេញ ការអភិវឌ្ឍន៏នៃដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ លទ្ធកម្ម ជំនាញគ្រប់គ្រងការិយាល័យ ជំរើស និង ជំនាញនៅការដោះស្រាយវិវាទ ដែលបានផ្តល់អោយដោយវិទ្យាស្ថានបណ្តុះបណ្តាលផ្នែកច្បាប់ និងយុត្តិធម៌ របស់ប្រទេសម៉ាឡេស៊ី និងកម្មវិធីកំព្យូទ័រ ដែលលោក *អ៊ី សំភី* ប្រធានផ្នែកបណ្តុះបណ្តាល និងទំនាក់ទំនង លោក *វណ្ណដេត តារារដ្ឋ* មន្ត្រីផ្នែកទំនាក់ទំនង និង លោក *ស ចេស្តា* មន្ត្រីផ្នែកច្បាប់ បានរៀនសូត្រពីគ្នាទៅវិញទៅមក អំពី DotNetNuke ដែលជាប្រព័ន្ធគ្រប់គ្រងមាតិការ (ដែលប្រើសំរាប់ការគ្រប់គ្រងគេហទំព័រ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជា។

នៅក្នុងឆ្នាំ ២០១០ មានសិក្ខាសាលា វគ្គបណ្តុះបណ្តាលមួយចំនួនដែលបានរៀបចំឡើងដោយ ទីប្រឹក្សាផ្នែកច្បាប់របស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីជាប្រយោជន៏ ដល់អាជ្ញាកណ្តាល បុគ្គលិករបស់មូលនិធិ និង លេខាធិការដ្ឋាន។ វគ្គបណ្តុះបណ្តាលនេះ គឺផ្តោតទៅលើការធ្វើអោយប្រសើរឡើងនូវជំនាញទំនាក់ទំនង និងគ្រប់គ្រង ដោយមានប្រធានបទដូចជា ការផ្តល់ និងការទទួលបានព័ត៌មានត្រលប់ (Giving and Receiving Feedback), Thinking on Your Feet, Time and Stress Manangement និងមេរៀនដែលចេញពីសៀវភៅគ្រប់គ្រង Living the Leadershipជាដើម។ កាលពីខែ វិច្ឆិកា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានចាប់ផ្តើមនូវកម្មវិធីណែនាំថ្មីមួយ ដោយការរៀបចំការប្រជុំគ្នា រវាងអាជ្ញាកណ្តាល និង សមាជិកបុគ្គលិកផ្នែកសេវាច្បាប់ ដូច្នេះ បទពិសោធន៏ដែល អាជ្ញាកណ្តាលមាន អាចជួយសេវាផ្នែកច្បាប់ ដើម្បីបង្កើតជំនាញ និង វិជ្ជាជីវៈផ្នែកច្បាប់របស់ខ្លួន។ មូលនិធិ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរំពឹងថា កម្មវិធីនេះ នឹងបន្តក្នុងរយៈពេលមួយឆ្នាំពេញ ដោយចាប់ផ្តើមពីខែ វិច្ឆិកា ឆ្នាំ ២០១០ ដល់ ខែ វិច្ឆិកា ឆ្នាំ ២០១១។

ជាលទ្ធផលពីការបណ្តុះបណ្តាល អាជ្ញាកណ្តាល និង បុគ្គលិកទាំងអស់បានរាយការណ៏ថា ជំនាញដែលខ្លួនបានរៀនសូត្រ តាមរយៈការណែនាំពីអ្នកជំនាញនៅក្នុងវិស័យនេះ បានជួយយ៉ាងច្រើន នៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល មូលនិធិ និង លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល អោយឆ្ពោះទៅរកការប្រសើរឡើងនៃការដោះស្រាយវិវាទការងារ និង នៅក្នុងការអនុវត្តន៏គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន។

## ***ការសាងភាពជាដៃគូរ***

មូលនិធិ និង ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបន្តរក្សាទំនាក់ទំនងល្អជាមួយនឹងត្រីភាគីសំខាន់ៗ ដែលមានសមាសភាពមកពី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហព័ន្ធសហជីព និងនិយោជក។ មូលនិធិក្រុមប្រឹក្សាកណ្តាលបានបង្កើតគណៈកម្មាធិការសហប្រតិបត្តិការរបស់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន (Project Collaboration Committee) ដើម្បីជួយដល់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល សំរាប់ការសម្របសម្រួលលើសកម្មភាពបំពេញ

បន្ថែម/រួមគ្នានានា តាមរយៈគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់ (Stakeholder Advisory Group) ប្រកបដោយជោគជ័យ និង បានហៅមកប្រជុំលើកដំបូង នៅការិយាល័យរបស់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល កាលពីថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០។ ក្នុងនោះមានអ្នកចូលរួមចំនួន ១១ រូប (២រូប មកពីសមាជិកនិមួយៗ នៃក្រសួងការងារ សហព័ន្ធសហជីព និយោជក និង ៥រូបជាបុគ្គលិករបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល)។ នៅក្នុងកិច្ចប្រជុំនេះ សមាជិកបានត្រួតពិនិត្យ លក្ខខ័ណ្ឌការងារ (Term of Reference) របស់សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ ការពិនិត្យមើលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយផ្តល់របាយការណ៍សកម្មភាពនានា ដែលស្ថិតក្រោមគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន ជំនួយសំរាប់អង្គភាពមិនមែនរដ្ឋ ដែលបានអនុវត្តដោយ *អង្គការមូលនិធិអាស៊ី* ក្រោមគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន ដើម្បីចូលរួមជាមួយ នឹងអង្គភាពមិនមែនរដ្ឋ ក្នុងការលើកស្ទួយអភិបាលកិច្ចល្អ ក្នុងភាពជាដៃគូជាមួយគ្រប់ភ្នាក់ងារអនុវត្តន៍គម្រោងទាំងអស់។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលរំពឹងថា ក្រុមប្រឹក្សាពិគ្រោះយោបល់ នឹងជួយធ្វើអោយប្រសើរ ឡើងនូវប្រសិទ្ធិភាពនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈការបង្កើតបណ្តាញសំរាប់ព័ត៌មានត្រលប់នានា ព្រមទាំងលើកស្ទួយការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដល់អ្នកពាក់ព័ន្ធសំខាន់ៗ តាមរយៈសមាជិកសមាគមន៍ និងបណ្តាញ។

នៅក្នុងឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរៀបចំការប្រជុំជាច្រើនដង ដើម្បីលើកស្ទួយកិច្ចសហការរវាងដៃគូរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរៀបចំ ការប្រជុំក្រៅផ្លូវការជាមួយនិង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិភាក្សាគ្នាលើការបណ្តុះបណ្តាលដែលចាំបាច់សំរាប់អ្នកផ្សះផ្សាររបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និងឱកាសសំរាប់ការបណ្តុះបណ្តាល ដោយអ្នកជំនាញអន្តរជាតិដែលបានមកធ្វើទស្សនៈកិច្ច។ នេះនាំមកនូវការបណ្តុះបណ្តាលសំរាប់មន្ត្រីផ្សះផ្សារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លើជំនាញផ្សះផ្សា ដោយអាជ្ញាកណ្តាលអូស្ត្រាលី នៅក្នុងខែ តុលា ឆ្នាំ ២០១០ ហើយនិងការសង្កេតមើលរបស់បុគ្គលិកមូលនិធិលើសវនការផ្សះផ្សា នៅឯក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅក្នុងខែ កញ្ញា ឆ្នាំ ២០១០។ កម្មវិធី “Meets & Greets” ចំនួនពីរដងរវាងតំណាងមកពីកម្មករ និង និយោជក ត្រូវបានរៀបចំឡើង ដើម្បីផ្តល់វេទិការដ៏មានសារៈប្រយោជន៍ សំរាប់កម្មករ និង និយោជកទាំងឡាយ អោយមានទំនាក់ទំនងគ្នាដោយផ្ទាល់ជាមួយនឹង អាជ្ញាកណ្តាល ក្នុងលក្ខណៈមិនមែនជាគូបដិបក្សនឹងគ្នា។ កំឡុងពេលនៃការជួបជុំគ្នាទាំងនេះ ពួកគេបានសំដែងនូវការដឹងគុណ ដល់ក្រុមប្រឹក្សាអាជ្ញកណ្តាល សំរាប់ដំណើរការដោះស្រាយវិវាទការងារ ប្រកបដោយយុត្តិធម៌ គួរអោយជឿជាក់ និងមានប្រសិទ្ធិភាព ព្រមទាំងធ្វើអោយមានកម្មវិធីសំរាប់បង្កើនសមត្ថភាព របស់បុគ្គលិកខ្លួន ក្នុងការរៀបចំ និង បង្ហាញសំណុំរឿង នៅក្នុងបើកសវនាការ។



*<u>រូបថតទី ៥:</u> កម្មវិធី "Meet & Greets" រវាងនិយោជិត និង អាជ្ញាកណ្តាល កាលពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១០*



*<u>រូបថតទី ៦:</u> កម្មវិធី "Meet & Greets" រវាងនិយោជក និង អាជ្ញាកណ្តាល កាលពីថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១០*

នៅក្នុងក៏រិតនៃគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចាប់ដៃគូជាមួយនឹងភ្នាក់ងារអនុវត្តគំរោងផ្សេងៗ ដូចជា វិទ្យុជាតិកម្ពុជារបស់ក្រសួងព័ត៌មាន ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ការិយាល័យច្រកចេញ-ចូលតែមួយ របស់ក្រសួងមហាផ្ទៃ និង អង្គការមូលនិធិអាស៊ី។ រហូតដល់ខែ ធ្នូ ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកសាងភាពជាដៃគូជាមួយនឹង ២៥ ស្ថាប័ន (រួមមានទាំងស្ថាប័នរដ្ឋ និង មិនមែនរដ្ឋ)។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាទំនាក់ទំនងជាមួយនឹងដៃគូ តាមរយៈអនុស្សារណៈនៃយល់យោគគ្នាដែលបង្កើតឡើង នូវទំនាក់ទំនង ដោយផ្តល់នូវចំនុចសំខាន់ៗ នូវកាតព្វកិច្ចរវាងគ្នាទៅវិញទៅមក។ រហូតដល់ខែ ធ្នូ ឆ្នាំ ២០១០ ដៃគូដែលមានអនុស្សារណៈនៃការយោគយល់គ្នាជាមួយនឹងមូលនិធិ មានដូចជា ក្រសួងទំនាក់ទំនងរដ្ឋសភា-

ព្រឹទ្ធសភា និងអធិការកិច្ច វិទ្យុជាតិកម្ពុជា, Australian Institute of Mediators Arbitrators និង សមាហរណ៏កម្មធនធានឆ្ពោះទៅគុណភាព (Integrating Human to Quality)។ ក្រៅពីតែអំពីដៃគូដែលមានអនុស្សារណៈនៃការយោគយល់គ្នា មូលនិធិបានបង្កើត និងរក្សាភាពជាដៃគូគ្នាជាមួយនឹងដៃគូផ្សេងទៀត ដូចជា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ Cambodian Center for Human Rights – Cambodian Business & Human Rights សមាគមរោងចក្រកាត់ដេរនៅកម្ពុជា មជ្ឍមណ្ឌលអាមេរិកាំងដើម្បីសាមគ្គីភាពការងារអន្តរជាតិ Australian Business Volunteers (ABV), Australian Industrial Relations Commission (AIRC) ដែលសព្វថ្ងៃនេះត្រូវបានគេស្គាល់ថាជា Fair Work Australia, Australian Volunteers International (AVI), អង្គការពលកម្មអន្តរជាតិ-គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា មជ្ឍមណ្ឌលអប់រំច្បាប់សំរាប់សហគមន៏ East-West Management Institute (EWMI), អង្គការពលកម្មអន្តរជាតិ-គម្រោងដោះស្រាយវិវាទការងារ (ILO-Labour Dispute Resolution Project), អង្គការពលកម្មអន្តរជាតិ-គម្រោងអប់រំ សាកលវិទ្យាល័យមេគង្គ សកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងសេដ្ឋកិច្ច សាកលវិទ្យាល័យកម្ពុជា រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និង ក្រុមអាជ្ញាកណ្ដាលមកបុស្តុន សហរដ្ឋអាមេរិក។

## ***ការផ្សព្វផ្សាយព័ត៌មាន***

ទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មាន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានបង្កើតគេហទំព័រមួយ គឺ www.arbitrationcouncil.org ដែលគេហទំព័រនេះគឺត្រូវបានគេ ធ្វើអោយប្រសើរឡើង ព្រមទាំងមានដំណើរការយ៉ាងល្អជាធម្មតា។ គេហទំព័រនេះបានផ្ដល់អោយនូវ អ្នកចូលទស្សនាពីព័ត៌មានសំខាន់ៗ របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាល និង លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ គេហទំព័រនេះមានផ្ទុកនូវព័ត៌មានដែលបានបោះផ្សាយអំពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ព័ត៌មានសំរាប់គូភាគី សេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល របាយការណ៏ និង និយ័តកម្ម ច្បាប់ការងារផ្សេងៗ សំរាប់ និយោជក សហជីព និង សាធារណៈជន។ គេហទំព័រនេះ មានជា បី ភាសា (ខ្មែរ អង់គ្លេស និង ចិន) ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកចូលទស្សនា។ លើសពីនេះទៀត គេហទំព័រ ផ្ដល់នូវព័ត៌មានបច្ចុប្បន្ន អំពីគំរោងអភិបាលកិច្ចល្អមូលដ្ឋានសមាសភាគដើម្បីគាំទ្រដល់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដូចជា ព័ត៌មានស្ដីពីគំរោងអភិបាលកិច្ចល្អមូលដ្ឋាន ការប្រកាសអំពីលទ្ធកម្ម ជាដើម។ល។ ដោយផ្អែកលើការ តាមដានលើគេហទំព័រនេះ បានបង្ហាញថា មានអ្នកចូលទស្សនា ចំនួន ១៦៣៥ នាក់ ដែលមកពីប្រទេសចំនួន ៤២ ដែលក្នុងនោះ អ្នកចូលទស្សនាភាគច្រើន (៨៣%) គឺនៅក្នុងប្រទេសកម្ពុជា។

*ចំនួនអ្នកចូលទស្សនាគេហទំព័ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងឆ្នាំ ២០១០*

| ល.រ | ប្រទេស | ចំនួនអ្នកទស្សនា | ភាគរយ |
|---|---|---|---|
| ***១*** | ***កម្ពុជា*** | ***១,៣៥៨*** | ***៨៣%*** |
| ២ | សហរដ្ឋអាមេរិក | ៥៤ | ៣% |
| ៣ | ជប៉ុន | ៣៣ | ២% |
| ៤ | អូស្រ្តាលី | ២៥ | ២% |
| ៥ | ចក្រភពអង់គ្លេស | ១៤ | ១% |
| ៦ | ម៉ាឡេស៊ី | ១៣ | ១% |
| ៧ | វៀតណាម | ១៣ | ១% |
| ៨ | សិង្ហបុរី | ១២ | ១% |
| ៩ | បារាំង | ១១ | ១% |
| ១០ | ស៊ុីស | ១០ | ១% |
| ១១ | ប្រទេសផ្សេងៗទៀត | ៩២ | ៦% |
| | **សរុប** | **១,៦៣៥** | **១០០%** |

នៅឆ្នាំ ២០១០ នៅក្នុងផ្នែកទិន្នន័យអំពីច្បាប់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបញ្ចប់ការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ ទិន្នន័យថ្មី ដែលគេបានយកមកប្រើសំរាប់ ស្រង់យកព័តិមានរាល់គ្រប់សំណុំរឿងទាំងអស់មុនបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអាចធ្វើរក្សាទុកព័តិមានយ៉ាងមានប្រសិទ្ធិភាព ទាក់ទងនិងសំណុំរឿងសំរាប់គោលបំណងសិក្សាស្រាវជ្រាវ និង តាមដាន។

ក្រៅអំពីការអាចទទួលបាននូវព័តិមានមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងការដោះស្រាយវិវាទការងារតាមរយៈគេហទំព័រ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរក្សាការចេញផ្សាយអំពី សេចក្តីបង្គាប់របស់អាជ្ញាកណ្តាល ជាឯកសារចំលងជូនទៅកាន់និយោជក សហជីព កម្មករ និង ភាគីពាក់ព័ន្ធផ្សេងៗទៀត។ សិស្ស/និស្សិត សាស្ត្រាចារ្យផ្នែកច្បាប់ អ្នកសិក្សាស្រាវជ្រាវផ្នែកច្បាប់ការងារ និងសាធារណៈជនដែលចាប់អារម្មណ៍អាចទទួលបាននូវការចងក្រងសេចក្តីបង្គាប់នៅ Monumen Books។ នេះគឺជាផ្នែកនៃកម្មវិធីសាកល្បងមួយរបស់មូលនិធិ ដើម្បីធ្វើអោយក្រុមប្រឹក្សាអាជ្ញាកណ្តាលមាននិរន្តភាព។ អំឡុងពេលនៃរបាយការណ៍នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបោះផ្សាយ កម្រងសេចក្តីបញ្ជា និង សេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១២, ១៣, ១៤ ជាភាសាខ្មែរ (ចំនួន ៥០០ ច្បាប់ សំរាប់លេខនិមួយៗ) និង លេខ ១១ ជាភាសាអង់គ្លេស (ចំនួន ២៥០ ច្បាប់)។

ជាមួយគ្នាផងដែរ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបោះពុម្ភផ្សាយ នូវសំភារៈ ដូចជា bookmarks (១៥០០ ច្បាប់) របាយការណ៍ប្រចាំ ២០០៩ (៥០០ ច្បាប់ជាភាសាខ្មែរ និង ៥០០ ច្បាប់ជាភាសាអង់គ្លេស) ស៊ីឌី

ចំនួន ១៥០០ច្បាប់ ខិតប័ណ្ណសំរាប់លើការរៀបចំសំណុំរឿងមុនពេលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល (ចំនួន ១០០០ ច្បាប់ សំរាប់ភាសាខ្មែរ ១០០០ ច្បាប់សំរាប់ភាសាអង់គ្លេស និង ១០០០ ច្បាប់ សំរាប់ភាសាចិន)។ សៀវភៅស្តីពីនីតិវិធីដោះស្រាយវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល (ចំនួន ១៥០០ច្បាប់ជាភាសាខ្មែរ និង ១៥០០ច្បាប់ជាភាសាអង់គ្លេស។ កូនសៀវភៅសំនួរ និង ចំលើយ (១៥០០ ច្បាប់ជាភាសាខ្មែរ ១៥០០ច្បាប់ជាភាសាអង់គ្លេស និង ១៥០០ ច្បាប់ជាភាសាចិន) និង សៀវភៅប្រវត្តិរូបសង្ខេប សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល (៥០០ ច្បាប់ជាភាសាខ្មែរ និង ៥០០ច្បាប់ ជាភាសាអង់គ្លេស)។

ក្នុងឆ្នាំ ២០១០ មូលនិធិក៏បានបង្ហាញខ្លួននៅក្នុងប្រព័ន្ធផ្សព្វផ្សាយផងដែរ ដើម្បីលើកស្ទួយការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងកម្មវិធីទូរទស្សន៍ លោកនាយកប្រតិបត្តិមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានគេអញ្ជើញអោយចូលរួមនៅក្នុងកិច្ចពិភាក្សាតុមូល ដែលបានរៀបចំដោយ ការិយាល័យសម្របសម្រួលគំរោង នៅស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា កាលពីថ្ងៃទី ១៨ សីហា ឆ្នាំ ២០១០។ កម្មវិធីនេះ គឺផ្តោតសំខាន់ទៅលើ អភិបាលកិច្ចល្អ និងរបៀបដែលក្រុមប្រឹក្សាអាជ្ញា កណ្តាលបានចូលរួមចំណែក ដើម្បីធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ច នៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានគេចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ជាតិកម្ពុជា កាលពីថ្ងៃទី ២៩ និង ៣០ ខែ សីហា ឆ្នាំ ២០១០។ បន្ថែមពីនេះទៀត លោកនាយកប្រតិបត្តិរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏ត្រូវគេអញ្ជើញអោយធ្វើជាវាគ្មិន នៅវិទ្យុមាតុភូមិយើង (អេហ្វ អឹម ១០១,២៥) ស្តីពី ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ការដោះស្រាយវិវាទការងារនៅប្រទេសកម្ពុជា។ លោកបានបញ្ជាក់អំពីសារៈសំខាន់នៃការរៀបចំសំណុំរឿងអោយបានល្អ និង ការបង្ហាញសំណុំរឿង ដោយភាគីវិវាទ ព្រមទាំង ដំណាក់កាលស្ងប់ស្ងាត់ អំឡុងពេលដំណើរនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល[១]។ ជាលទ្ធផល កម្មវិធីនេះបានទទួល នូវអ្នកទូរស័ព្ទចូលមួយចំនួនពីបណ្តាខេត្ត ដូចជា ភ្នំពេញ ព្រះសីហនុ និងខេត្តកណ្តាល។ ក្នុងវគ្គសំនួរ-ចំលើយជាមួយវាគ្មិន អ្នកទូរស័ព្ទចូលបានរៀនសូត្រ ថាហេតុអ្វីបានជាវាមានសារៈសំខាន់សំរាប់គូភាគី ដើមរៀបចំ និងបង្ហាញសំណុំ រឿងរបស់ខ្លួន យ៉ាងប្រុងប្រយ័ត្ន និងមានប្រសិទ្ធិភាព មុនបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ថាតើខ្លួនឯងអាច ធ្វើអ្វីបាន ហើយពួកគេអាចធ្វើអ្វីនៅពេលបន្ទាប់ ប្រសិនបើក្រុមប្រឹក្សាបិទសំណុំរឿង ដោយសារមូលហេតុនៃការ ធ្វើកូដកម្ម។

លើសពីនេះទៀត បណ្ណាល័យរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបើកជាសាធារណៈ កាលពីពាក់កណ្តាលខែ មករា ឆ្នាំ ២០១០ សំរាប់ អ្នកមកពីខាងក្រៅ ព្រមទាំងបានទទួលបានអ្នកអានខ្លះៗ ផង ដែរ។ ក្នុងកំឡុងពេលនៃរបាយការណ៍ បណ្ណាល័យនេះបានទទួល សៀវភៅ ព័ត៌មាន និង ទស្សនាវដ្តី ដែលទាក់ទិន និងអាជ្ញាកណ្តាលច្បាប់មុខរបរ និង ការរីសអើង ដំណោះស្រាយវិវាទ ច្បាប់ការងារនិង មុខរបរ និងទំនាក់ទំនងក្នុងវិស័យឧស្សាហកម្មពី ស៊ូសាន ប្រោន ដែលជាអាជ្ញាកណ្តាលការងារ កាមីន រេស ជាមេធាវី នៅបូស្តុន ម៉ាសាឈូសេត សហរដ្ឋអាមេរិក លោក រ៉ូសម៉ារី អេ ថោនលី និង លោក អាណុល ហ្សាក់ ជាអាជ្ញាកណ្តាល និងអ្នកផ្សះផ្សាផ្នែកមុខរបរ និង ការងារនៅសហរដ្ឋអាមេរិក។

---

[១] មិនត្រូវមានកូដកម្ម ឬ ឡុកអៅ អំឡុងពេលនៃការផ្សះផ្សារ ឬ សម្របសម្រួលវិវាទ ដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។

ជាមួយគ្នាផងដែរ កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរៀបចំសន្និសីទថ្នាក់ជាតិលើកទី ៥ ស្តីពីទំនាក់ទំនងវិជ្ជាជីវៈ នៅសណ្ឋាគារសាន់វេ។ ប្រធានបទឆ្នាំនេះ គឺ *ការចរចាអនុសញ្ញារួម ដើម្បីទំនាក់ទំនងវិជ្ជាជីវៈកាន់តែប្រសើរៈ ដំណោះស្រាយរួម ចំពោះបញ្ហាប្រឈម នាពេលបច្ចុប្បន្ន*។ សន្និសីទនេះ មានអ្នកចូលរួមប្រមាណ ១៨០នាក់ មកពីអង្គភាពផ្សេងៗ ដូចជា សហជីពពាណិជ្ជកម្ម សមាគមន៍និយោជក ក្រុមហ៊ុនឯកជន អង្គការពលកម្មអន្តរជាតិ ស្ថានទូតនានា អង្គការសង្គមស៊ីវិល និងអង្គការដែលកំពុងធ្វើការងារក្នុងវិស័យទំនាក់ទំនងវិជ្ជាជីវៈ។ សន្និសីទនេះ ត្រូវបានភ្នាក់ងារយកព័ត៌មានមួយចំនួនដូចជា កាសែតស្ថាបនា កាសែតកោះសន្តិភាព ទូរទស្សន៍បាយ័ន និងវិទ្យុមហានគរ។




*<u>រូបថតទី ៧:</u> សន្និសីទថ្នាក់ជាតិលើកទី ៥ ស្តីពីទំនាក់ទំនងវិជ្ជាជីវៈ កាលពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១០*

### ***ការបណ្តុះបណ្តាលសម្រាប់ភាគីដែលពាក់ព័ន្ធ***

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានខិតខំយ៉ាងខ្លាំង ដើម្បីបង្កើនការយល់ដឹងដល់ភាគីពាក់ព័ន្ធ ស្តីអំពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដំណើរការដោះស្រាយវិវាទការងារនៅប្រទេសកម្ពុជា។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានផ្តល់នូវវគ្គបណ្តុះបណ្តាលជាច្រើនដល់ភាគីរបស់ខ្លួន។ ជាក់ស្តែង ក្នុងឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានដូចជាៈ (១) បច្ចេកទេសនៃការចរចា សំរាប់និយោជិត/និយោជក ចំនួន ៣៦រូប និង ការដោះស្រាយវិវាទការងារ សំរាប់កម្មកររោងចក្រកាត់ដេរ ចំនួនប្រមាណ ១០០រូប ក្រុមប្រឹក្សាអាជ្ញាកណ្តាល អ្នកផ្សះផ្សារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៣០រូប ដែលមកពីខេត្តចំនួន ៨។ (២) របៀប រៀបចំសំណុំរឿងប្រកបដោយប្រសិទ្ធិភាពសំរាប់អាជ្ញាកណ្តាល និង ដំណោះស្រាយវិវាទការងារនៅកម្ពុជា (មេធាវី ៦១ រូប)។ (៣) ការបណ្តុះបណ្តាលរួមគ្នា រវាង មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ ទៅកាន់បុគ្គលិកផ្នែកច្បាប់របស់មជ្ឈមណ្ឌលអាមេរិកាំង ដើម្បីសាមគ្គីភាពការងារអន្តរជាតិ និងអ្នកតស៊ូមតិរបស់សហព័ន្ធសហជីព (១៥រូប)។ (៤)

វគ្គពីរផ្សេងគ្នា "ការដោះស្រាយវិវាទការងារ" និង "ការដោះស្រាយវិវាទការងារ និង ក្រុមប្រឹក្សាអាជ្ញាកណ្តាល" ដល់និស្សិតច្បាប់ (ប្រមាណ ៤២៦រូប)។ (៥) ជំនួយការច្បាប់ សំរាប់បុគ្គលិករបស់ មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ អំពីរបៀបរៀបចំសំណុំរឿងសំរាប់ការបើកសវនាការរបស់អាជ្ញាកណ្តាល។ (៦) បុគ្គលិកផ្នែកធនធានមនុស្ស និង រដ្ឋបាល (ច្រើនជាង ៣៥រូប) មកពីរោងចក្រកាត់ដេរផ្សេងៗ ស្តីពីការរៀបចំនិង បង្ហាញសំណុំរឿងជាមុន សំរាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ (៧) អង្គការក្រៅរដ្ឋាភិបាលនានា នៅកម្ពុជា (៥០រូប) ស្តីពី ដំណើរការដោះស្រាយវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល។ (៨) អ្នកអប់រំផ្នែកច្បាប់ (១៧រូប) ស្តីពី វគ្គបណ្តុះបណ្តាលគ្រូបង្គោលលើក្របខ័ណ្ឌច្បាប់ សំរាប់ការចរចាអនុសញ្ញារួមនៅកម្ពុជា។ (៩) អ្នកផ្សះផ្សា (៣០រូប) របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីបច្ចេកទេសផ្សះផ្សា ដោយផ្តោតសំខាន់លើវិធីផ្សះផ្សាវិវាទដ៏ល្អ បំផុតរវាងសហជីព និង សហជីព របៀបដើម្បីចរចារលើអនុសញ្ញារួម និងរបៀបបញ្ចុះបញ្ចូលភាគី ដើម្បីអនុវត្ត ជាមួយនឹងអនុសញ្ញារួមដែលពួកគេមានស្រាប់។ (១០) សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ (ប្រមាណ ១០០រូប) ស្តីពី បច្ចេកទេសផ្សះផ្សា។



*<u>រូបថតទី ៨:</u> វគ្គចែករំលែកព័ត៌មានស្តីពី អនុស្សារណៈនៃការយោគយល់គ្នា ដល់ភាគីពាក់ព័ន្ធ កាលពីថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១០*

ប្រធានបទ អនុស្សារណៈនៃការយោគយល់គ្នាស្តីពីការធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ នៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២៨ កញ្ញា ឆ្នាំ ២០១០ រវាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ជាមួយនឹងសហព័ន្ធសហជីព និងសម្ព័ន្ធសហជីពធំៗ ទាំង ៦ គឺជាចំនុចសំខាន់ ដែលការងារបង្ហាត់បង្រៀនបានផ្តល់អោយ ដល់ភាគីពាក់ព័ន្ធទាំងឡាយ។ អនុស្សារណៈនៃការយោគយល់គ្នានេះ

ថ្លែងពី សេចក្ដីបង្គាប់ជាប់កាតព្វកិច្ច ដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល សំរាប់វិវាទការងារអំពីសិទ្ធិ ដែលមានន័យថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងត្រូវការកែប្រែនីតិវិធីនូវចំនុចជាក់លាក់មួយចំនួន ដើម្បីសម្របសម្រួលដល់ការអនុវត្ត អនុស្សារណៈនៃការយោគយល់គ្នា ដែលនឹងមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១១។ ដូចនេះ មានវគ្គបង្ហាត់បង្រៀនចំនួន ៥ សំរាប់ប្រធានបទនេះ ដែលបានធ្វើឡើងនៅក្នុង ខែធ្នូ ឆ្នាំ ២០១០ សំរាប់ដៃគូរបស់ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដូចជា មជ្ឈមណ្ឌលអាមេរិកាំងសំរាប់សាមគ្គីការងារអន្ដរជាតិ មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់ សហគមន៍ និងមជ្ឈមណ្ឌលព័ត៌មានកម្មករ មន្ត្រីផ្នែកការងារនៃគូភាគីអនុស្សារណៈនៃការយោគយល់គ្នា សកម្មជន សហជីព បុគ្គលិកផ្នែកធនធានមនុស្ស/រដ្ឋបាលនៃសហគ្រាស ដែលតំណាងសំណុំរឿងមុនបញ្ជូនមកក្រុមប្រឹក្សាអាជ្ញា កណ្ដាល។ តាមលទ្ធផលនៃកិច្ចប្រជុំទាំងនោះ អ្នកចូលរួមអបរអំពីការអញ្ជើញអោយចូលរួមរបស់ មូលនិធិក្រុម ប្រឹក្សាអាជ្ញាកណ្ដាល និង សរសើរដល់ភារកិច្ច ដើម្បីចែករំលែក និង ផ្សព្វផ្សាយព័ត៌មានទាំងអស់ដល់ខ្លួន។ ម្យ៉ាងវិញទៀត អ្នកចូលរួមបានបញ្ជាក់ថា ការបង្ហាត់បង្រៀនទាំងនោះគឺមានតម្លាភាព។ ជាចុងក្រោយ ភាគីពាក់ព័ន្ធស្នើអោយមានវគ្គបង្ហាត់បង្រៀនផ្សេងៗជាបន្តទៀត។

## ***ការសិក្សាអំពីអាជ្ញាកណ្ដាលនៅក្នុងសកម្មភាពការតាមដាន និងវាយតម្លៃ***

កំឡុងពេលនៃរបាយការណ៍នេះ មូលនិធិក្រុមប្រឹក្សាបានបញ្ចប់ការសិក្សាចំនួនពីរ គឺ *ការសិក្សាស្រាវជ្រាវ ទិន្នន័យគោល* (Baseline Study) និង *តំរូវការសំរាប់សេវាកម្មរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល* (Demand for AC Service) ចំណែកឯការសិក្សាមួយទៀតហៅថា Study to Quantify the AC value គឺស្ថិតក្នុងដំណើរការលទ្ធកម្ម នៅឡើយ។

តាមរយៈសកម្មភាពតាមដានទាំងនេះ អំឡុងពេលនៃរបាយការណ៍នេះ មានលទ្ធផលសំរេចបានសំខាន់ៗមួយ ចំនួនត្រូវបានរកឃើញ។ ក្នុងចំណោមសូចនាករណ៍ទាំងអស់នៃលទ្ធផលរបស់គំរោង មានសូចនាករណ៍ចំនួន *បួន* ដែលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាលតាមរយៈការស្រាវជ្រាវរបស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានរកឃើញនៅក្នុង ការសិក្សាស្រាវជ្រាវទិន្នន័យគោល។ ការសិក្សានេះ ភ្នាក់ងារស្រាវជ្រាវធ្វើការសិក្សាស្រាវជ្រាវជាមួយនឹងអតិថិជន និង មិនមែនអតិថិជនរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដោយគិតទាំង សហជីពកម្មករ សហព័ន្ធសហជីព និង និយោជក។ សូមពិនិត្យមើលនូវលទ្ធផលសង្ខេប ដូចបានរៀបរាប់ខាងក្រោមនេះ :

- <u>សូចនាករណ៍ទី ១</u>: ការកំណត់អំពីកិរិតយល់ដឹងពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺត្រូវបានវាស់វែង។ អ្នកតបសម្ភាសន៍ភាគច្រើន បានចង្អុលបង្ហាញថា ខ្លួនបានស្គាល់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល (១០០% គឺជា អតិថិជន ចំណែកឯ ៩២% គឺមិនមែនជាអតិថិជន)។ បន្ថែមពីនេះទៀត ៤៥%នៃអ្នកតបសម្ភាសន៍ ទទួលស្គាល់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលតាមរយៈ សហព័ន្ធ/សម្ព័ន្ធកម្មករ ប៉ុន្តែ តាមប្រព័ន្ធផ្សព្វផ្សាយគឺ ២៧% ក្រសួងការងារ ២០% មិត្តភ័ក្រ/អ្នករួមការងារ ១១% និងតាមមធ្យោបាយផ្សេងៗទៀត (ដូចជា ធ្លាប់ចូល រួមការបង្ហាត់បង្រៀន ដែលរៀបចំឡើងដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល ធ្លាប់ចូលរួមក្នុងសវនការនៅ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល)។ម្យ៉ាងវិញទៀត អ្នកតបសម្ភាសន៍ ៦១% បានបញ្ជាក់ថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺជាស្ថាប័នមួយដែលដោះស្រាយវិវាទការងារ ដោយឡែក ១៣% ដឹងថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ជាអ្នកបើកសវនការស្ដីពីវិវាទការងារ។ ចំណែកអំពីតួនាទីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល អ្នកតបសម្ភាសន៍ភាគច្រើន បានដឹងថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺកំពុងធ្វើការងារលើការដោះស្រាយវិវាទការងារ (៧៧%) ជាពិសេស សម្រាប់វិវាទការងាររួមតែប៉ុណ្ណោះ (៧៣%)។ ៧៧% នៃអ្នកតបសម្ភាសន៍បានដឹងថា សេវារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺត្រូវបានផ្ដល់អោយដោយឥតគិតថ្លៃ។

- <u>សូចនាករណ៍ទី ២:</u> ដើម្បីនឹងវាស់វែងលើកម្រិតយល់ដឹងអំពីដំណើការមជ្ឍត្តិកម្មការងារ គឺមានសំណួរមួយចំនួន ត្រូវបានគេសួរដូចជា ដំណើការនៃការដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល របៀបដែលវិវាទការងារមកដល់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងការធ្វើសេចក្ដីសម្រេចចិត្តដោយអាជ្ញាកណ្ដាល និងភាពអាចធ្វើបាននៃការជំទាស់ទៅនឹងសេចក្ដីសម្រេច។ ជាលទ្ធផល អ្នកតបសម្ភាសន៍ភាគច្រើន (៧៥%) បានយល់ដឹងអំពីដំណើការមជ្ឍត្តិកម្មការងារ ដោយសារតែគេមានបទពិសោធន៍ចូលរួមនៅក្នុងការបណ្ដុះបណ្ដាល និងសវនការ។ អ្នកតបសម្ភាសន៍ ៧០% គឺបានដឹងអំពីរបៀបវិវាទការងារ ដែលត្រូវបានគេដោះស្រាយតាមរយៈការផ្សះផ្សារផ្ទៃក្នុង សហព័ន្ធសហជីព ហើយនឹងទៅ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មុននឹងបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ លើសពីនេះទៀត អ្នកតបសម្ភាសន៍ ៨៧% បានយល់អំពីក្រុមអាជ្ញាកណ្ដាល ដែលបានសម្រេចចិត្តទៅលើសំណុំរឿង នៅឯក្រុមប្រឹក្សាអាជ្ញាកណ្ដាលទៀតផង។
- <u>សូចនាករណ៍ទី ៣:</u> គឺថា ការកំណត់នៃកម្រិតនៃទុកចិត្តលើ ភាពឯករាជ្យ ភាពអាចជឿជាក់ និងប្រសិទ្ធិភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ យោងតាមលទ្ធផលនៃការស្រាវជ្រាវបានរកឃើញថា អ្នកតបសម្ភាសន៍ភាគច្រើន (៨៩%) បង្ហាញថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលគឺស្ថាប័នឯករាជ្យមួយ ដោយសារតែវាមិនលំអៀងទៅភាគីណាមួយ និងគ្មានជះឥទ្ធិពលដោយភាគីណាមួយឡើយ។ ជាក់ស្ដែង អ្នកតបសម្ភាសន៍បានរាយការណ៍ថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺមានឯករាជ្យភាពជាង បើប្រៀបធៀបជាមួយនឹងប្រព័ន្ធតុលាការ (៨១%) ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ប៉ូលីស និងដទៃផ្សេងទៀត ពីព្រោះក្រុមប្រឹក្សាអាជ្ញាកណ្ដាលគឺងាយស្រួលទៅដល់ ឯករាជ្យពីភាគីផ្សេងៗទៀត មានប្រសិទ្ធិភាពដើម្បីដោះស្រាយវិវាទ គួរអោយទុកចិត្តបាននៅក្នុងការដោះស្រាយវិវាទ ការងារមានតម្លាភាព ចំណេញពេលវេលា និងដំណើការឆាប់រហ័ស។ ចំណែកឯភាពអាចជឿជាក់បានវិញ អ្នកតបសម្ភាសន៍ភាគច្រើន សំដែងថា ការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គឺធ្វើឡើងអាស្រ័យតាមអង្គហេតុ ការអះអាង និងច្បាប់ដែលទាក់ទិននានា។ អ្នកតបសម្ភាសន៍បានវាយតំលៃកម្រិតខ្ពស់ផងដែរចំពោះប្រសិទ្ធិភាពរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ពីព្រោះរាល់សេចក្ដីសម្រេចទាំងអស់ គឺផ្អែកលើការចចារគ្នា ការព្រមព្រៀង និងតម្លាភាព។
- <u>សូចនាករណ៍ទី ៤:</u> ការសិក្សាស្រាវជ្រាវទិន្នន័យគោលនេះ បានសិក្សាលើកម្រិតនៃភាពជឿជាក់នៅក្នុងសមត្ថភាពស្ថាប័នរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីអនុវត្តការងារដោះស្រាយវិវាទការងារ។ យោងតាម

របាយការណ៍នេះ អ្នកតបសម្ភាសន៍ភាគច្រើន (៩២%) បានឆ្លើយថា ពួកគេដឹងថា អាជ្ញាកណ្តាលមានចំណេះដឹងជ្រៅជ្រះអំពីឧស្សាហកម្មកម្ពុជា។ ជាពិសេស អ្នកតបសម្ភាសន៍បានវាយតំលៃខ្ពស់ចំពោះជំនាញដោះស្រាយវិវាទការងារ ការពន្យល់បានច្បាស់លាស់អំឡុងពេលសវនការ និងសេចក្តីសម្រេច គឺធ្វើឡើងដោយលាយលក្ខណ៍ជាអក្សរច្បាស់លាស់ និងអាចយល់បាន។

ការមានការសិក្សាស្រាវជ្រាវផ្សេងមួយទៀត ដែលវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ត្រូវបានគេជ្រើសរើសអោយធ្វើការសិក្សាអំពីតម្រូវការសំរាប់សេវាកម្មក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ការសិក្សានេះត្រូវបានគេធ្វើឡើងនៅតំបន់ភូមិសាស្ត្របី គឺ ខេត្ត កំពង់ចាម ព្រះសីហនុ និង សៀមរាប ដោយផ្អែកតាមការវាយតម្លៃសេដ្ឋកិច្ចអាជីវកម្មតាមខេត្ត-ក្រុង (២០០៦-២០០៩)។ ការស្រាវជ្រាវបានបង្ហាញថា ខេត្តសៀមរាបអាចទីកន្លែងសមស្របសំរាប់ការឈានចូលជាពិសេសវិស័យបដិសណ្ឋារកិច្ច និងទេសចរណ៍ ដើម្បីអោយក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចពង្រីកសេវាកម្មរបស់ខ្លួននៅតំបន់នេះបាន។ ជាក់ស្តែង អ្នកតបសម្ភាសន៍ចំនួន ២៥នាក់ (ឬ៦០%) ក្នុងចំណោម ៤២នាក់ នៅក្នុងខេត្តសៀមរាប បានសំដែងនូវចំណាប់អារម្មណ៍ជាមួយនឹងសេវាកម្មរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នេះ គឺបង្ហាញពីលទ្ធភាពនៃការពង្រីកសេវាកម្មរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងរក្សានូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់សេវាកម្មទៅកាន់ខេត្តនានាតាមតម្រូវការ។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលរំពឹងថាសេវាកម្មនានា នឹងត្រូវផ្តល់អោយចាប់ពីឆ្នាំ ២០១១ តទៅ។

សព្វថ្ងៃនេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានពិភាក្សា និង កំណត់យកវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodian Development Research Institute) ដើម្បីកំណត់ពីទំហំនៃការសិក្សា ស្រាវជ្រាវ និងអ្វីៗ ដែលទាក់ទងនឹងការងារស្រាវជ្រាវនេះ។ ការសិក្សានេះរំពឹងថា នឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំ ២០១១។ សំរាប់សំភារៈចាក់ផ្សព្វផ្សាយ (ឈុតវីដេអូអប់រំ) មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ចប់រួចរាល់ ដំណើការលទ្ធកម្មជាមួយធនាគារពិភពលោក។ ខណៈពេលនេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល និង មជ្ឈមណ្ឌលស្ត្រី កម្ពុជា បានព្រមព្រៀងគ្នា និងបានចុះហត្ថលេខាលើកិច្ចសន្យា កាលពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១០ ដើម្បីនឹងផលិតនូវ ស្ពតអប់រំមួយ នឹង វីដេអូអប់រំមួយ។ ផលិតផលនៃឈុតវីដេអូអប់រំ នេះរំពឹងនឹងបញ្ចប់នៅពាក់កណ្តាលខែ តុលា ឆ្នាំ ២០១១។ ចំណែកឯ Sustainability Study ត្រូវបានគេពន្យាដោយសារ តែការសិក្សានេះនឹងត្រូវគេចាប់ផ្តើម បន្ទាប់ពីបញ្ចប់ការសិក្សា Study on the value of AC services។ ដូចគ្នាដែរ Sustainability and Fundraising Consultant គឺរំពឹងថា នឹងចាប់ផ្តើមធ្វើសកម្មការរៃអង្គាសថវិកា បន្ទាប់ពីមានលទ្ធផលនៃការសិក្សា Study on the value of AC service។

## គ. សកម្មភាពសំខាន់ៗ

| **មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាល (ACF) 2010** | |
|---|---|
| **ត្រីមាសទី១** | ➢ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានរៀបចំការប្រជុំអាជ្ញាកណ្ដាល ដើម្បីរាយការណ៍អំពីលទ្ធផលសំរេចបានឆ្នាំ ២០០៩ និងសំណុំរឿងវិវាទការងារសំខាន់ៗ |
| | ➢ ថ្ងៃទី ៣០ ខែ មករា រហូតដល់ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ នៅខេត្តព្រះសីហនុ ជាមួយអាជ្ញាកណ្ដាល លេខាធិការដ្ឋានក្រុមប្រឹក្សា អាជ្ញាកណ្ដាល |
| | ➢ នៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ មន្ត្រីហិរញ្ញវត្ថុបានចូល វគ្គបណ្ដុះបណ្ដាលស្ដីពី " **ច្បាប់សារពើពន្ធ** " ដែលរៀបចំដោយ សហព័ន្ធនិយោជក និងសមាគមន៍ពាណិជ្ជកម្មកម្ពុជា |
| | ➢ ថ្ងៃទី ០៥ ខែ កុម្ភៈ ២០១០ អាជ្ញាកណ្ដាល គង់ ផល្លៈ បានផ្ដល់វគ្គបណ្ដុះបណ្ដាលស្ដីពី **"បច្ចេកទេសផ្សះផ្សា"** ដល់សមាជិក ក្រុមប្រឹក្សា ឃុំ/សង្កាត់ |
| | ➢ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចុះកិច្ចសន្យាជាមួយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ស្ដីពីសិក្សាពីតំរូវនៃការផ្ដល់សេវារបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល |
| | ➢ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញា កណ្ដាលបានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី **"ការដោះស្រាយវិវាទ ការងារ"** ដល់និស្សិតនៃមជ្ឈមណ្ឌលភាសាជប៉ុនរបស់ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច |
| | ➢ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១០ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានរៀបចំឡើង ដើម្បីផ្ដល់ព័ត៌មានអំពីករណីសំណុំរឿងសំខាន់ៗ |
| | ➢ ថ្ងៃទី ១៥-១៩ ខែ មីនា ឆ្នាំ ២០១០ អ្នកបណ្ដុះបណ្ដាលអន្តរជាតិ បានផ្ដល់ការបណ្ដុះបណ្ដាលដល់មន្ត្រីមូលនិធិ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងលេខាធិការដ្ឋាន ភាគីពាក់ព័ន្ធ ព្រមទាំងមន្ត្រីមកពីក្រសួងការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលទទួលបន្ទុកផ្នែកដោះស្រាយវិវាទការងារនៅកម្ពុជា ស្ដីពីការដោះស្រាយវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្ដាល |
| **ត្រីមាសទី២** | ➢ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១០ ក្រុមការងារសំរាប់ **"សេចក្ដីណែនាំអំពីការបង្ហាញភស្តុតាង"** ត្រូវបានបង្កើតឡើងដោយ មានតំណាងមកពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល មន្ត្រីលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងមន្ត្រីផ្នែកសេវា |

| | |
|---|---|
| | ច្បាប់របស់មូលនិធិ |
| | ➢ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១០ កិច្ចប្រជុំជាទៀងទាត់រវាង ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល និងមន្ត្រីផ្នែកសេវាច្បាប់របស់មូលនិធិ បានធ្វើឡើងដើម្បីពិភាក្សាគ្នា អំពីការពង្រាងសេចក្តីបង្គាប់ |
| | ➢ ថ្ងៃទី ២២ ខែ មេសា ២០១០ បុគ្គលិករបស់មូលនិធិ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញា កណ្តាលបានទទួលបានវគ្គបណ្តុះបណ្តាលអំពី "**អគ្គីភ័យ**" |
| | ➢ ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១០ ទីប្រឹក្សាផ្នែកច្បាប់១រូប ត្រូវបានជ្រើសរើសដើម្បីពិនិត្យ និងរៀបចំបទបង្ហាញសំរាប់ផ្តល់ ការបណ្តុះបណ្តាលដល់បុគ្គលិកមូលនិធិ ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងលេខាធិការ ដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| | ➢ ថ្ងៃទី ១០-១២ ខែ ឧសភា ឆ្នាំ ២០១០ ផ្នែកមន្ត្រីរដ្ឋបាល ហិរញ្ញវត្ថុ និងផ្នែកបណ្តុះបណ្តាល បានចូលរួមវគ្គបណ្តុះបណ្តាល "**យេនឌ័រ**" ដែល បានរៀបចំដោយអង្គការសីលការ ក្រោមកិច្ចសហការគ្នាជាមួយនឹងការិយាល័យសម្របសម្រួលគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន |
| | ➢ ថ្ងៃទី ២២-២៩ ខែ ឧសភា ឆ្នាំ ២០១០ អាជ្ញាកណ្តាលចំនួនបីរូប នាយកមូលនិធិ ១រូប មន្ត្រីផ្នែកសេវាច្បាប់ ១រូប មន្ត្រីលេខាធិការដ្ឋាន ១រូប និងអគ្គនាយកនាយកដ្ឋានរបស់ក្រសួងការងារ បានធ្វើទស្សនៈកិច្ចសិក្សានៅសហរដ្ឋអាមេរិក ដើម្បីផ្លាស់ប្តូរបទពិសោធន៏ទាក់ទិន នឹងជំនាញការវិស័យទំនាក់ទំនងវិជ្ជាជីវៈ |
| | ➢ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ មន្ត្រីផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាល បានចូលរួមកិច្ចប្រជុំហិរញ្ញវត្ថុមួយ នៅការិយាល័យសម្របសម្រួលគម្រោង ដើម្បីរៀបចំ "**របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន** (Interim Financial Report) " តាមតម្រូវការរបស់ធនាគារពិភពលោក |
| | ➢ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០ មន្ត្រីផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាល បានចូលរួមកិច្ចប្រជុំស្តីពី **"E-signature** និងការធ្វើ **Withdrawal Application"** ដើម្បីរៀបចំឡើងដោយធនាគារពិភពលោក និង ក្រសួងសេដ្ឋកិច្ច និង ហិរិញ្ញវត្ថុ |
| | ➢ ក្នុងខែ ឧសភា ឆ្នាំ ២០១០ ព្រឹត្តិប័ត្រសំរាប់ឆមាសទី ១ របស់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបោះផ្សាយនិងចែកជូនដល់ សមាជិកគ្រួសារក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| | ➢ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ លោកនាយកប្រតិបត្តិនៃមូលនិធិបាន ផ្តល់វគ្គបណ្តុះ |

| | |
|---|---|
| | បណ្តុលដល់និស្សិតច្បាប់ ចំនួន ២០នាក់ ស្តីពី "**ការដោះស្រាយវិវាទការងារ និងតួនាទីរបស់ក្រុមប្រឹក្សា អាជ្ញាកណ្តាល**" |
| | ➢ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១០ កិច្ចប្រជុំអាជ្ញាកណ្តាល ជាមួយបុគ្គលិកមូលនិធិ និងលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានរៀបចំឡើងនៅ ការិយាល័យ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីពិភាក្សាគ្នាអំពី: (១) **តួនាទីរបស់ក្រុមប្រឹក្សា អាជ្ញាកណ្តាល នៅក្នុងប្រព័ន្ធដោះស្រាយវិវាទនៅកម្ពុជា** និង (២) **ការប្រមូលភស្តុតាង**។ |
| | ➢ ថ្ងៃទី ២២-២៣ ខែ មិថុនា ឆ្នាំ ២០១០ មន្ត្រីផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី "**លទ្ធកម្ម** (Procurement)" ដែលរៀបចំដោយ ធនាគារពិភពលោក និងក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | ➢ នៅថ្ងៃទី ២៣-២៥ ខែ មិថុនា ឆ្នាំ ២០១០ បុគ្គលិកទទួលភ្ញៀវរបស់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានរួមវគ្គបណ្តុះបណ្តាលស្តីពី "**ជំនាញគ្រប់គ្រង ការិយាល័យ**" នៅការិយាល័យសមាហរណ៍កម្ម ធនធានឆ្ពោះទៅគុណភាព |
| | ➢ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ កិច្ចប្រជុំសំរាប់ក្រុមប្រឹក្សាពិគ្រោះយោបល់ ត្រូវបានរៀបចំឡើងនៅការិយាល័យមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមានការ ចូលរួមពីសមាជិក ក្រុមប្រឹក្សាភិបាលរបស់សហព័ន្ធនិយោជកនិងសមាគម ពាណិជ្ជកម្មកម្ពុជា អនុប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍និង សេវាកម្ម ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា អនុប្រធាននាយកដ្ឋានអធិការ កិច្ចការងារ និងអគ្គនាយករងនៃនាយកដ្ឋាន ការងាររបស់ក្រសួងការងារ ដើម្បី ពិនិត្យ មើលលក្ខន្តិកៈការងាររបស់សមាជិក ទស្សនៈវិស័យរបស់មូលនិធិ និងក្រុម ប្រឹក្សាអាជ្ញាកណ្តាល របាយការណ៍សកម្មភាពរបស់គម្រោងអភិបាលកិច្ចល្អមូលដ្ឋាន |
| | ➢ ថ្ងៃទី ២១ មិថុនា ដល់ ១ កក្កដា ឆ្នាំ ២០១០ លោកអាជ្ញាកណ្តាល ប៉ែន ប៊ុនឈា បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី "**ជំរើស និងជំនាញ នៅក្នុងការដោះស្រាយវិវាទ** (Options and Skills in Dispute Resolution)" ដែលរៀបចំឡើងដោយ Malaysia’s Judicial and Legal Training Institute |
| | ➢ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានរៀបចំវគ្គ បណ្តុះបណ្តាលស្តីពី "**ជំនាញ និងដំណើការ ដោះស្រាយវិវាទការងារ**" ដល់បុគ្គលិក ផ្នែករដ្ឋបាល និងធនធានមនុស្ស ចំនួនជាង ២០នាក់ ដែលមកពីបណ្តារោងចក្រនានា |
| | ➢ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០ នាយកប្រតិបត្តិរបស់មូលនិធិត្រូវ បានអញ្ជើញ អោយចូលរួមក្នុងកម្មវិធីវិទ្យុសន្ទនាមតិ ស្តីពី "**ដំណើការ ដោះស្រាយវិវាទ** |

| | |
|---|---|
| | **ការងារនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ សំលៀកបំពាក់**" ដែលបានរៀបចំនិងផ្សាយផ្ទាល់ដោយវិទ្យុជាតិកម្ពុជា |
| | ➢ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១០ លោក អ៊ុំ សំភី ប្រធានផ្នែកបណ្តុះបណ្តាល និងទំនាក់ទំនង បានឡើងធ្វើបទបង្ហាញអំពី ដំណើការដោះស្រាយវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដល់អ្នកចូលរួមចំនួនប្រមាណ ៥០នាក់ មកពីបណ្តាអង្គការក្រៅរដ្ឋាភិបាលនានានៅកម្ពុជា ត្រូវបានការិយាល័យសម្របស ក្រោមការអញ្ជើញរបស់ការិយាល័យសម្របសម្រួលគំរោងអភិបាលកិច្ចល្អមូលដ្ឋាន |
| | ➢ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១០ លោក ហ៊ូហ្គូវ៉ាន់ណ៍ ទីប្រឹក្សាផ្នែកច្បាប់របស់មជ្ឈមណ្ឌលអាជ្ញាកណ្តាលជាតិ លោក ហាន់ ហ្វង ទីប្រឹក្សាជាន់ខ្ពស់ផ្នែកបច្ចេកទេស និងច្បាប់របស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ខេត ប៊ូហ្គេចា អតីតទីប្រឹក្សាផ្នែកច្បាប់របស់មូលនិធិ បានធ្វើបទបង្ហាញពិសេសមួយស្តីពី "**ក្រុមប្រឹក្សាអាជ្ញាកណ្តាលកម្ពុជា : A Castle in the Air**" ដល់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល អាជ្ញាកណ្តាល និង មន្ត្រីលេខាដ្ឋាន ប្រមាណ ៤០រូប |
| | ➢ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១០ មូលនិធិ បានរៀបចំកិច្ចប្រជុំអាជ្ញាកណ្តាល (RAM) នៅការិយាល័យរបស់ខ្លួន ដើម្បីផ្សព្វផ្សាយអំពីសកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗ ដូចជា ការបោះពុម្ភរបាយការណ៍ប្រចាំឆ្នាំ ផែនការទស្សនកិច្ចរបស់លោកអាជ្ញាកណ្តាល ម៉ៃឃើលហ្គេ នៅចុងខែ កញ្ញា និងដើមខែ តុលា |
| | ➢ ថ្ងៃទី ២៧-២៨ ខែ កក្កដា ឆ្នាំ ២០១០ បុគ្គលិកមូលនិធិក្រុម ប្រឹក្សាអាជ្ញាកណ្តាល បានចូលរៀនវគ្គ DotNetNuke និង Content Management System ដើម្បីគ្រប់គេហទំព័រ ។ |
| | ➢ ក្នុងខែ កក្កដា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានរៀបចំកិច្ចប្រជុំក្រៅផ្លូវការជាមួយនឹង មន្ត្រីសំខាន់ៗរបស់ក្រសួង ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជា លោក ហួន សឿ អគ្គនាយករងនៃនាយកដ្ឋានដោះស្រាយវិវាទការងារ និងលោក ជា សៀងហេង ប្រធានការិយាល័យដោះស្រាយវិវាទការងារ ដើម្បីពិភាក្សាគ្នាលើតំរូវការចាំបាច់ និងការកសាងសមត្ថភាព សំរាប់មន្ត្រីផ្សះផ្សារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **ត្រីមាសទី៣** | ➢ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០១០ លោក អ៊ុំ សំភី ប្រធានផ្នែកបណ្តុះបណ្តាល និងទំនាក់ទំនង បានឡើងធ្វើបទបង្ហាញអំពី ដំណើការដោះស្រាយវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដល់អ្នកចូលរួមចំនួនប្រមាណ ៥០នាក់ មកពីបណ្តាអង្គការក្រៅ |

| | |
|---|---|
| | រដ្ឋាភិបាលនានានៅកម្ពុជា ក្រោមការអញ្ជើញរបស់ ការិយាល័យសម្របសម្រួលគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន |
| | ➢ ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១០ កញ្ញា ជុំ ចរិយា មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់របស់មូលនិធិ បានរៀបចំបទបង្ហាញមួយដល់ និស្សិតច្បាប់ចំនួន ៤៦រូប ស្តីពី **"ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ការដោះស្រាយវិវាទការងារ"** |
| | ➢ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១០ មូលនិធិ បានជ្រើសរើសអ្នកបើកបរម្នាក់ អោយចូលធ្វើការងារ សម្រាប់គំរោងអភិបាលកិច្ចល្អមូលដ្ឋាន |
| | ➢ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ លោកអាជ្ញាកណ្តាល **គង់ ផល្លះ** បានធ្វើបទបង្ហាញមួយដល់ បុគ្គលិកផ្នែករដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស ចំនួន ១៥រូប មកពីក្រុមហ៊ុន ស្តីពី **"ការរៀបចំ និងបង្ហាញសំណុំរឿងមុនបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល"** |
| | ➢ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១០ មូលនិធិបានរៀបចំឡើងនូវកម្មវិធី *Meet & Greet* ដើម្បីផ្តល់ឱកាសដល់សហជីពសំខាន់ចំនួន ៣០ រូបបានជួបនូវអាជ្ញាកណ្តាល ដើម្បីជជែកគ្នាអំពីបញ្ហាទាក់ទិននឹងការដោះស្រាយវិវាទការងារ និង ក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| | ➢ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ លោកអាជ្ញាកណ្តាល **គង់ ផល្លះ** បានធ្វើបទបង្ហាញមួយស្តីពី **"ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ការ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា"** ដល់និស្សិតច្បាប់ ១០រូប ក្រោមកម្មវិធីឧបត្ថម្ភរបស់ EWMI សំរាប់និស្សិតនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ |
| | ➢ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០ លោកនាយកប្រតិបត្តិរបស់មូលនិធិ ត្រូវបានទូរទស្សន៍ជាតិកម្ពុជា អញ្ជើញអោយចូលរួមក្នុងកម្មវិធីពិភាក្សា តុមូលស្តីពី **"អភិបាលកិច្ចល្អ និង ក្រុមប្រឹក្សាអជ្ញាកណ្តាល ចូលរួមចំណែក ដើម្បីធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចនៅកម្ពុជា"** |
| | ➢ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ កិច្ចប្រជុំរបស់គណៈកម្មាធិការ សហប្រតិបត្តិគម្រោង បានរៀបចំឡើងនៅក្រសួងការងារ ដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានជម្រាបជូនអំពី *១) ការរៀបចំ អំពីវគ្គបណ្តុះបណ្តាលដល់អ្នកផ្សះផ្សារស្តីពី បច្ចេកទេសផ្សះផ្សារ ដែលនឹងធ្វើឡើងដោយ អាជ្ញាកណ្តាល ម៉ៃឃើលហ្គើ ២) សន្និសីទថ្នាក់ជាតិស្តីពីទំនាក់ទំនងវិជ្ជាជីវៈ និង ៣) ការផ្តល់អំណោយនូវ កំព្យូទ័រចំនួន ១០គ្រឿង របស់ Fair Work Ombudsman ដល់អ្នកផ្សះផ្សាររបស់ក្រសួងការងារ* |

| | |
|---|---|
| | ➢ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១០ លោក **អ៊ី សំភី** ប្រធានផ្នែកបណ្តុះបណ្តាល និងទំនាក់ទំនង បានផ្តល់វគ្គបណ្តុះសំរាប់គ្រូបង្គោលស្តីពី "**ក្របខ័ណ្ឌច្បាប់សំរាប់ការចចាររួមនៅកម្ពុជា**" ដល់អ្នកអប់រំ ១៧រូបមកពីសហព័ន្ធសហជីពផ្សេងៗគ្នា ដែលជាផ្នែកមួយនៃគម្រោងរបស់អង្គការពលកម្មពិភពលោក - គម្រោងដោះស្រាយវិវាទការងារនៅក្រៅប្រព័ន្ធតុលាការ |
| | ➢ ក្នុងខែ សីហា ឆ្នាំ ២០១០ មូលនិធិបានបញ្ជូន មន្ត្រីរដ្ឋបាលនិងហិរញ្ញវត្ថុ និងមន្ត្រីសម្របសម្រួលការបណ្តុះបណ្តាល បានចូលរួមវគ្គស្តីពី "**លទ្ធកម្ម**" ដែលរៀបចំដោយការិយាល័យសម្របស្រមួលគម្រោង អភិបាលកិច្ចល្អមូលដ្ឋាន |
| | ➢ ក្នុងខែ សីហា ឆ្នាំ ២០១០ មូលនិធិបានបញ្ជូន លោក ប៉ែន សាវ៉ាត និង អ៊ឹង សារ៉ាវុធ បានចូលរួមវគ្គស្តីពី "**ការកសាងភាពជាដៃគូ**" ដែលរៀបចំដោយ ការិយាល័យសម្របសម្រួលគម្រោងអភិបាលកិច្ចល្អ មូលដ្ឋាន នៅសណ្ឋាគារកាំបូឌីយ៉ាណា |
| | ➢ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១០ មូលនិធិបានរៀបចំឡើងនូវកម្មវិធី *Meet & Greet* ដើម្បីផ្តល់ឱកាសដល់តំណាងនិយោជក សមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា សំខាន់ចំនួន ៣0 រូបបានជួបនូវអាជ្ញាកណ្តាល ដើម្បីជជែកគ្នាអំពី បញ្ហាទាក់ទិន នឹងការដោះស្រាយវិវាទការងារ និង ក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| | ➢ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ មូលនិធិបានជ្រើសរើសអ្នកស្ម័គ្រចិត្ត បរទេស ១រូប ឈ្មោះ **អេជេលីកា នីកូឡូសុន** (Angelica Nikolausson) សំរាប់បំរើការងាររយៈពេល ៣ សប្តាហ៍ ដើម្បីជួយផ្នែកសេវាច្បាប់ |
| | ➢ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០ អ្នកនាង **គីម ស៊ុនយ៉ា** ទីប្រឹក្សាផ្នែកច្បាប់របស់មូលនិធិ បានផ្តល់វគ្គបណ្តុះបណ្តាល ដល់និស្សិត ផ្នែកច្បាប់ និងពាណិជ្ជកម្ម ៥0រូប ស្តីពី ការដោះស្រាយវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| | ➢ ថ្ងៃទី ២១-២២ ខែ កញ្ញា ឆ្នាំ ២០១០ មូលនិធិបានរៀបចំតូបមួយនៅ ឯ DI Forum ដែលធ្វើឡើងសណ្ឋាគារអ៊ិនធឺខនធីណេនថល ដើម្បីចែកជូននូវឯកសារដូចជា សៀវភៅស្តីពីការដោះស្រាយវិវាទការងារនិងក្រុមប្រឹក្សាអាជ្ញាកណ្តាល ខិតប័ណ្ណស្តីពីការរៀបចំសំណុំ រឿងមុន បញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល សៀវភៅសំនួរ-ចំលើយ |
| | ➢ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០ មូលនិធិ រៀបចំកិច្ច ប្រជុំមួយជាមួយ នឹងអាជ្ញាកណ្តាល ដើម្បីជម្រាបជូនអំពី ដំណើរ ទស្សនកិច្ចរបស់លោកអាជ្ញាកណ្តាលម៉ៃឃើលហ្គើ |

| | |
|---|---|
| | ➢ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល និង សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា រួមគ្នារៀបចំសវនការប្រឌិត ដើម្បីបង្ហាញ អំពីដំណើការទូទៅនៃសវនការអាជ្ញាកណ្តាល នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយមាន អ្នកចូលរួមជាង ១០០ នាក់ ដែលជានិស្សិតផ្នែកច្បាប់ ពាណិជ្ជកម្ម និងសមាជិកអង្គការ ក្រៅរដ្ឋាភិបាលនានា |
| | ➢ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១០ លោកម៉ៃឃើលហ្គើ ត្រូវបានអញ្ជើញដើម្បីពិនិត្យ មើលនូវគំរូនៃសេចក្តីបង្គាប់ និងផ្តល់ ព័ត៌មានត្រលប់វិញ |
| | ➢ ខែ កញ្ញា ឆ្នាំ ២០១០ មូលនិធិបានបោះផ្សាយនូវឯកសារ ដូចជា *សីមីចំនួន* ១៥០០ច្បាប់, *របាយការណ៍ប្រចាំឆ្នាំ ២០០៩* (៥០០ច្បាប់ សំរាប់ភាសាខ្មែរ និង ៥០០ច្បាប់សំរាប់ភាសាអង់គ្លេស) ក្របដាក់ ឯកសារ ចំនួន ១៥០០ច្បាប់ ខិតប័ណ្ណស្តីពី ការរៀបចំសំណុំរឿង មុនបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល (៥០០ ច្បាប់ជា ភាសាខ្មែរ ៥០០ច្បាប់ជាភាសាអង់គ្លេស និង ៥០០ច្បាប់ជាភាសាចិន) សៀវភៅ តូចស្តីពី ការដោះស្រាយវិវាទការងារនិងក្រុមប្រឹក្សា អាជ្ញាកណ្តាល (១៥០០ច្បាប់ជា ភាសាខ្មែរ ១៥០០ច្បាប់ជាភាសា អង់គ្លេស) និង សៀវភៅសំនួរនិងចំលើយ (១៥០០ច្បាប់ជាភាសាខ្មែរ ១៥០០ច្បាប់ជា ភាសាអង់គ្លេស និង ១៥០០ ច្បាប់ជាភាសាចិន) |
| | ➢ ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១០ មូលនិធិបានរៀបចំ សន្និសីទថ្នាក់ជាតិ លើកទី ៥ ស្តីពីទំនាក់ទំនងវិជ្ជាជីវៈ ក្រោមប្រធានបទ **"ការចរចារ អនុសញ្ញារួម ដើម្បី ទំនាក់ទំនងវិជ្ជាជីវៈកាន់តែប្រសើរៈ *ដំណោះស្រាយរួមចំពោះបញ្ហាប្រឈម នាពេលបច្ចុប្បន្ន*"** ដោយមានការចូលរួមពីសំណាក់ តំណាងសហជីព សមាគមនិយោជក ក្រុមហ៊ុនឯកជន អង្គការពលកម្មអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និង ស្ថានទូតនានា |
| | ➢ ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានរៀបចំកិច្ចប្រជុំ សំរាប់អាជ្ញាកណ្តាល ស្តីពីដំណើទស្សនកិច្ចរបស់ លោក ម៉ៃឃើលហ្គើ |
| | ➢ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបោះពុម្ពនូវសេចក្តីបង្គាប់ជា ភាសាខ្មែរ វ៉ុល លេខ ១២, ១៣, ១៤ ចំនួន ៥០០ច្បាប់សម្រាប់វ៉ុល និមួយៗ |
| | ➢ ខែ តុលា ឆ្នាំ ២០១០ មូលនិធិបានរៀបចំកាផ្តល់អំណោយរបស់ Fair Work Ombudsman តាមរយៈ Fair Work Australia កំព្យូទ័រចំនួន ៥ គ្រឿង ដល់មន្ត្រីផ្សះផ្សារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **ត្រីមាសទី៤** | ➢ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានជ្រើសរើស |

| | |
|---|---|
| | លោក **ប៊ុន វុឌ្ឍី** អោយចូលបំរើការងារជា អ្នកសម្របសម្រួលផ្នែកតាមដាន និងវាយតម្លៃ របស់មូលនិធិ ក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| | ➢ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សា អាជ្ញាកណ្តាល បានរៀបចំកិច្ចប្រជុំសំរាប់អាជ្ញាកណ្តាល នៅសណ្ឋាគារឡាផារ៉ានដា ដើម្បីពិភាក្សាគ្នាអំពី អនុសារណៈនៃការយោគយល់គ្នា លើការធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងវិស័យវិជ្ជាជីវៈ ដែលត្រូវជ្រើសរើស យក សេចក្តីបង្គាប់ជាប់កាតព្វកិច្ច |
| | ➢ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ លោកនាយកមូលនិធិក្រុមប្រឹក្សា អាជ្ញាកណ្តាល ត្រូវបានអញ្ជើញអោយចូលរួមជាវាគ្មិននៅក្នុងកម្មវិធី ទូរស័ព្ទចូល របស់ប៉ុស្តិ៍វិទ្យុ អេហ្វអឹម ១០១.២៥ ស្តីពី **"ក្រុមប្រឹក្សាអាជ្ញាកណ្តាល និង ការដោះស្រាយវិវាទការងារ"** |
| | ➢ ថ្ងៃទី ២៩ វិច្ឆិកា ដល់ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០ គណៈប្រតិភូដែល រួមមាន អ្នកស្រី **បូ ច័ន្ទវាំសនា** ប្រធានលេខាដ្ឋានក្រុមប្រឹក្សាអាជ្ញា កណ្តាល លោក **វណ្ណដេត តារារដ្ឋ** មន្ត្រីផ្នែកទំនាក់ទំនង អ្នកស្រី **ស៊ូ សោភា** ប្រធានផ្នែកសេវាច្បាប់ និង កញ្ញា **យូ សួនទី** អាជ្ញាកណ្តាល បានធ្វើទស្សនកិច្ចសិក្សានៅ Fair Work Australia ប្រទេសអូស្ត្រាលី |
| | ➢ ខែ វិច្ឆិកា ឆ្នាំ ២០១០ មូលនិធិ បានជ្រើសរើសអ្នកកែផ្នែកច្បាប់ និងអ្នកបកប្រែឯកសារច្បាប់ ដើម្បីធ្វើការបកប្រែ និងកែ លើសេចក្តី បង្គាប់លេខ ១៣ |
| | ➢ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១០ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបាន រៀបចំការប្រជុំក្រុមប្រឹក្សាភិបាល ដើម្បីពិភាក្សាលើបញ្ហា (១) រាយការណ៍ពីសកម្មភាពសំរាប់ខែ កក្កដា-វិច្ឆិកា ២០១០, (២) របាយការណ៍ហិរិញ្ញវត្ថុ និង(៣) អនុស្សរណៈនៃការយោគយល់គ្នារបស់ ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ |
| | ➢ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១០ លោក អាជ្ញាកណ្តាល គង់ ផល្លៈ ត្រូវបានអញ្ជើញអោយចូលរួមក្នុងសន្និសីទ Alternative Pathways to Justice ដែលរៀបចំឡើងដោយ UNDP នៅសណ្ឋាគារ Imperial Garden |
| | ➢ ថ្ងៃទី ១៧-១៩ ខែ ធ្នូ ឆ្នាំ ២០១០ មូលនិធិ បានរៀបចំកិច្ចការ ប្រជុំប្រចាំឆ្នាំ ដែលមានការចូលរួមពីសំណាក់បុគ្គលិក របស់មូលនិធិ អាជ្ញាកណ្តាល និង លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល |
| | ➢ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១០ មូលនិធិ បានចុះកិច្ចសន្យា ជាមួយមជ្ឈមណ្ឌលស្ត្រីកម្ពុជា ដើម្បីផលិតសំភារៈ ផ្សព្វផ្សាយចំនួនពីរ |
| | ➢ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ អាជ្ញាកណ្តាល បុគ្គលិកមូលនិធិ និងលេខាធិការដ្ឋាន |

| | |
|---|---|
| | បានចូលរួមសំដែងការគួរសមឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | ➢ ខែធ្នូ ឆ្នាំ ២០១០ នាយកមូលនិធិ និងប្រធានផ្នែកបណ្តុះបណ្តាល និងទំនាក់ទំនង បានជួបប្រជុំគ្នាជាមួយលោក **វ៉ាន់ ស៊ូអៀង** ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងបុគ្គលិករបស់ សមាគម ដើម្បីពិភាក្សាគ្នាអំពីយុទ្ធសាស្ត្រសំរាប់អនុវត្តអនុស្សរណៈ នៃការយោគយល់គ្នាក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់លើសេចក្តីបង្គាប់ចងកាតព្វកិច្ច |
| | ➢ ខែធ្នូ ឆ្នាំ ២០១០ មូលនិធិបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៥ វគ្គ ផ្សេងៗគ្នា លើប្រធានបទ **"ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអនុសារណៈ នៃការយោគយល់គ្នាក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ លើសេចក្តីបង្គាប់ចងកាតព្វកិច្ច"** ដល់ភាគីពាក់ព័ន្ធអោយបានជ្រាប |
| | ➢ ខែធ្នូ ឆ្នាំ ២០១០ មូលនិធិបានបោះផ្សាយនូវ ព្រឹត្តិប័ត្រប្រចាំត្រីមាសទី ៣ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៥០០ ច្បាប់ និងបានចែកជូន ដល់ភាគីពាក់ព័ន្ធ |

## ឃ. បញ្ហាប្រឈម និងវិធានការដោះស្រាយ

| បញ្ហាជួបប្រទះ | បានដំណោះស្រាយ | សំណើរដោះស្រាយពី PMT |
|---|---|---|
| ការសិក្សាមួយចំនួនត្រូវបានពន្យាពេលដោយសារការជ្រើសរើសអ្នកជំនាញការមានការយឺតយ៉ាវ និងដោយសារគម្រោងពន្យាពេលអនុវត្តន៍ | ដាក់ការសិក្សាទាំងនោះទៅអនុវត្តន៍នៅឆ្នាំ ២០១១ | |
| ការផលិតឯកសារផ្សព្វផ្សាយពីក្រុមប្រឹក្សាអាជ្ញាកណ្តាលដល់ក្រុមគោលដៅត្រូវលើកពេល | នឹងចាប់ផ្តើមនៅឆ្នាំ ២០១០ | |

## ង. សន្និដ្ឋាន និងទិសដៅបន្ត

នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចការងារសំខាន់ ឆ្លើយតបទៅនឹង គោលបំណងអភិវឌ្ឍន៏គម្រោង ដោយការអនុវត្តន៍នូវសកម្មភាពសំខាន់ៗ ដោយរួមបញ្ចូល

ការរៀបចំវគ្គនានា សម្រាប់អភិបាលកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល កិច្ចប្រជុំប្រចាំឆ្នាំរបស់មូលនិធិ និង ក្រុមប្រឹក្សាអាជ្ញាកណ្តាល សវនការដោះស្រាយវិវាទការងារ ការរៀបចំទស្សនកិច្ចសិក្សាអោយមានអ្នកបង្ហាត់បង្រៀនបរទេស សម្រាប់ការកសាងសមត្ថភាពដល់អាជ្ញាកណ្តាល បុគ្គលិករបស់មូលនិធិ និង លេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងភាគីពាក់ព័ន្ធ ( មានជាអាទិ៍ ដូចជា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និយោជក និង សហព័ន្ធសហជីព ...។ល។)។ ជាទូទៅ បើប្រៀបធៀបគ្នារវាងវឌ្ឍនភាពការងារជាមួយនឹងផែនការអនុវត្តគម្រោង មានសកម្មភាពចំនួន ៥៧ ដែលបានលើកឡើង នៅក្នុងផែនការអនុវត្តន៍គម្រោង នៅក្នុងឆ្នាំ ២០១០។ ក្នុងនោះ មានសកម្មភាពចំនួន ៤១ (ឬ៧២%) គឺត្រូវបានអនុវត្តចប់សព្វគ្រប់ ១០ (ឬ១៨%)សកម្មភាពទៀត គឺកំពុងអនុត្តបន្ត និង ៦ (ឬ១០%) សកម្មភាពទៀត មិនទាន់បានអនុវត្ត និង/ឬត្រូវលើកទៅឆ្នាំ ២០១១។ លើសពីនេះទៀត មាន ២០ចំនុចគោល ដែលបានដាក់ស្នើនៅក្នុងផែនការឆ្នាំ ២០១០។ ជាលទ្ធផលក្នុងចំណោមនេះ មាន ១៤ (ឬ៧0%) គឺត្រូវបានអនុវត្តចប់សព្វគ្រប់ ១ (ឬ៥%)សកម្មភាពទៀត គឺកំពុងអនុត្តបន្ត និង ៥ (ឬ២៥%) សកម្មភាពទៀត មិនទាន់បានអនុវត្ត និង/ឬត្រូវលើកទៅឆ្នាំ ២០១១។ ចំពោះចំនុចនានាដែលនៅសេសសល់ គឺកំពុងតែ ដំណើការ ឬ ត្រូវបានគេលើកទៅសម្រាប់ការអនុវត្តន៍ នៅក្នុងឆ្នាំ ២០១១ ដូចជា ការសិក្សាមួយចំនួន លើការសិក្សាលើតម្លៃសេដ្ឋកិច្ច ចិរភាព ការរៃអង្គាសមូលនិធិ និង ការអភិវឌ្ឍន៍សម្ភារៈផ្សព្វផ្សាយ។ អ្វីដែលគួរអោយកត់សំគាល់នោះគឺ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ចប់ការសិក្សាចំនួនពីរគឺ ការសិក្សាទិន្និន័យគោល និង តំរូវការសម្រាប់សេវាកម្មអាជ្ញាកណ្តាល។ ការសិក្សាទាំងពីរនេះ បង្ហាញអំពីវាយតំលៃខ្ពស់លើ ការស្គាល់ ការយល់ដឹង កិត្តិយសរាជ្យ ភាពជឿទុកចិត្ត ប្រសិទ្ធិភាព និង តំបន់ដែលមានសក្តានុពលភាព សម្រាប់ពង្រីកសេវាកម្មនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

សម្រាប់លទ្ធផលសុច្ចនាករណ៍នានា មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចគោលដៅចំនួន ១៤៥ សំណុំរឿង ដែលស្មើនឹង ១០ភាគរយតិចជាងចំនួនដែលគ្រោងនៅក្នុងឆ្នាំ ២ (១៦៣ សំណុំរឿង) ដោយសារតែការសហជីពពីរសំខាន់ៗ គឺឈ្មោះ សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និង សហព័ន្ធសហជីពយុវជនខ្មែរ បានបំបែកខ្លួនទៅជា សហជីពតូចៗ ដែលខ្វះការរៀបចំ និងប្រសិទ្ធិភាព ក្នុងការប្តឹងពីវិវាទការងារ។ *មូលហេតុទីពីរ* សហជីព និង កម្មករ បានព្យាយាមដោះស្រាយ វិវាទការងាររបស់ខ្លួននៅកំរិតរោងចក្រ ជៀសជាងនៅស្ថាប័នផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ អត្រាដោះស្រាយវិវាទការងារដោយជោគជ័យ គឺស្មើ នឹង ៧០.១១% កើនឡើង បើប្រៀបទៅនឹងឆ្នាំ ២០០៩ (៦៥%)។ មានសុច្ចនាការណ៍ចំនួនពីរផ្សេងទៀត ដែលមិនអាចសម្រេចបានផែនការ គឺ (១) ចំនួនសំណុំរឿងដែលទទួលបានក្រៅពីទីក្រុងភ្នំពេញនិងខេត្តកណ្តាល គឺមានចំនួន ១% តិចជាងចំនួនដែលគ្រោង ចំណែក សំណុំរឿងដែលទទួលបានក្រៅពីវិស័យកាត់ដេរ គឺស្មើនឹង ១២%។ ប្រភពនៃសំណុំរឿង គឺស្ថិតនៅក្រៅការគ្រប់គ្រងផ្ទាល់ពីមូលនិធិ/ក្រុមក្រុមប្រឹក្សាអាជ្ញាកណ្តាល។ យ៉ាងណាក៏ដោយ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងខិតខំប្រឹងប្រែងអោយអស់ពីលទ្ធភាព ដើម្បីបំពេញការងារទាំងអស់ ដែលមាននៅក្នុងផែនការប្រចាំឆ្នាំ ២០១១ ហើយរំពឹងថា ទាំងសុច្ចនាករណ៍លទ្ធផល និងទិន្នផល នឹងត្រូវបានប្រសើរឡើង។